# កិច្ចសំភាសន៍របស់លោកតាឈ្មោះ រស់ រ៉េត

កៈ អ្នកសំភាសន៍ឈ្មោះ ហេង សុជីវី ខៈ អ្នកដែលត្រូវសំភាសន៍ឈ្មោះ រស់ រ៉េត

កៈ ចាសជាដំបូងសូមជំរាបសួរលោកតា!

ខៈ សាធុ សាធុ សាធុចៅ!

កៈ ចាសលោកតាថ្ងៃនេះចៅមានឧកាសដើម្បីបានមកធ្វើការសំភាសន៍លោកតាផ្ទាល់!

ខៈ បាទចៅ!

កៈ ហើយចៅធ្វើការស្ម័គ្រចិត្តនៅខាងគំរោងរបស់សាលា BYU ហាវ៉ៃនៅខាងសហរដ្ឋអាមេរិច

ខៈ បាទចៅ!

កៈ
ហើយគំរោងមួយរបស់ខាងសាលាមួយនឹងគឺគេជួយចងក្រងពង្សប្រវត្តិរបស់ប្រជាជនកម្ពុជាដែលពួកគាត់មានវ័យចាប់ពី៣៥ឆ្នាំឡើយទៅ
អំពីជីវប្រវត្តិអំពីប្រវត្តិរូបរបស់ពួកគាត់ណាស់លោកតា.....

ខៈ បាទចៅ!

កៈ
ទីកន្លែងកំណើតក៏ដូចជាបទពិសោធន៍ដែលគាត់ធ្លាប់បានឆ្លងកាត់តាំងពីមុនរហូតមកដល់ឥលូវនឹងថាតើពួកគាត់ធ្លាប់បានឆ្លងកាត់នូវបទពិសោធន៍នៅក្នុងជីវិតអីខ្លះដើម្បីនឹងបានយកមកធ្វើការចែកចាយទៅដល់កូនចៅជំនាន់ក្រោយអោយគេបានស្តាប់អញ្ចឹងណាស់លោកតា!

ខៈ បាទៗចៅ!

កៈ ចាសលោកតា!
អញ្ចឹងថ្ងៃនេះចៅមានឪកាសដើម្បីនឹងមកធ្វើការសំភាសន៍លោកតាផ្ទាល់អញ្ចឹងតើលោកតាអនុញ្ញាតអោយចៅធ្វើការសំភាសន៍លោកតាដែរឬទេ?

ខៈ បាទៗចៅ បានណាស់ចៅ!

កៈ ចាសលោកតា! (មានសំលេងរំខានពីខាងក្រៅ)!

ខៈ តាំង...តាំងពីអ៊ុំបានកើតមកទានណាស់...

កៈ ចាសលោកតា!

ខៈ បាទតាំងពីឆ្នាំ១៩០០...ប៉ុន្មានទេតាអត់ចាំទេចៅសាមសិបប៉ុន្មានទេ...៣៨ (ឆ្នាំ ១៩៣៨)!

កៈ ចាសលោកតា!

ខៈ បាទចៅ! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ហើយជាកិច្ចការសំភាសន៍នឹងគឺធ្វើឡើងនៅក្នុងថ្ងៃទី២៤ ខែ៧ឆ្នាំ២០១៨!

ខៈ បាទចៅ!

កៈ ហើយខ្ញុំឈ្មោះហេង សុជីវី គឺជាអ្នកសំភាសន៍លោកតាផ្ទាល់តែម្តង!

ខៈ បាទចៅ!

កៈ
ហើយជាកិច្ចដំបូងនៃការសំភាសន៍ចៅសុំសួរឈ្មោះរបស់លោកតាជាមុនសិនតើលោកតាមានអ្វីដែរលោកតា?(មានសំលេងរំខានពីខាងក្រៅ)!

ខៈ បាទខ្ញុំបាទឈ្មោះ លោកតា រស់ រ៉េត!

គៈ ឈ្មោះ តារ៉េត!

កៈ អូ...ចាសលោកតា!
ហើយទៅឈ្មោះរបស់លោកតានឹងត្រូវនឹងអត្តសញ្ញាណប័ណ្ណដែរឬទេលោកតា?

ខៈ បាទត្រូវនឹងអត្តសញ្ញាណប័ណ្ណម៉ងចៅ! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ហើយទៅលោកតាដាក់អត្តសញ្ញាណប័ណ្ណមកដែរឬទេលោកតា?

ខៈ មានដាក់មកតើចៅ!

កៈ
អញ្ចឹងចៅសូមថតអត្តសញ្ញាណប័ណ្ណរបស់លោកតាមួយដើម្បីអោយអឺ...វាច្បាស់ម៉ងណាស់លោកតា!

ខ៖ បាទចៅ!

ក៖ ចាសលោកតា! អញ្ចឹងខ្ញុំបានប្រគល់អត្តសញ្ញាណប័ណ្ណជូនទៅលោកតាវិញហើយ! ហើយទៅលោកតាមានឈ្មោះហៅក្រៅដែរឬទេលោកតា? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បាទហៅឈ្មោះហៅក្រៅនឹងអត់មានទេចៅ មានតែឈ្មោះ រស់ រ៉េត នឹងម៉ងចៅអត់មានឈ្មោះហៅក្រៅទេចៅ! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា! ហើយទៅឈ្មោះរបស់លោកតានឹងមានអត្តន័យយ៉ាងម៉េចដែរលោកតា?

ខ៖ ឈ្មោះនឹងជាឈ្មោះពីកំណើត ដែលតាំងពីយើងកើតមកនឹងគឺម៉ែឪពួកគាត់បានដាក់ឈ្មោះនឹងអោយអញ្ចឹងណាស់ចៅ!

ក៖ ចាសលោកតា!

ខ៖ បាទ គាត់ដាក់ឈ្មោះអោយតានឹង រស់ រ៉េត តែប៉ុណ្ណឹងទេណាស់!

ក៖ ចាសលោកតា! ហើយនឹងលោកតាមានអាយុប៉ុន្មានឆ្នាំហើយលោកតា?

ខ៖ បាទឆ្នាំតាមានអាយុ....

គ៖ អាយុ ៨១ឆ្នាំ (សំលេងពីខាងក្រៅ)!

ខ៖ ៨១ឆ្នាំហើយណាស់ចៅ!

គ៖ គាត់នឹង៨១ឆ្នាំហើយ (សំលេងរបស់លោកយាយ)!

ក៖ ចាសលោកតា! ហើយទៅលោកតាកើតនៅក្នុងឆ្នាំណាដែរលោកតា?

ខ៖ កើតនៅក្នុងឆ្នាំ ១៩៣៨!

ក៖ អូ...

ខ៖ បាទចៅ!

ក៖ ចាសលោកតាហើយទៅលោកតាមាននៅចាំឆ្នាំជាឆ្នាំចន្ទគតិរបស់ខ្មែរយើងណាស់លោកតាកើតនៅក្នុងឆ្នាំអីដែរលោកតា? (មាសសំលេងរំខានពីខាងក្រៅ)!

ខ៖ អូ...នៅក្នុងឆ្នាំ១៩៣៨ នឹងខ្ញុំអត់បានកត់ទុកមិនដឹងថានៅក្នុងឆ្នាំអីទេចៅ(សើច)!

ក៖ ឆ្នាំ...

ឃ៖ យាយអើយ...(សំលេងរបស់មនុស្សប្រុស)!

ក៖ ឆ្នាំដូចជាឆ្នាំសត្វណាស់លោកតាដូចជាឆ្នាំ ជូត ឆ្លូវ ខាល ថោះអីណាស់លោកតា!

គ៖ យាយអើយធ្វើអី?
នៅយប់មិញនឹងមានក្មេងៗភ្លេចកាបូបនៅចោល.....(សំលេងរបស់មនុស្សប្រុស)!

ក៖ ចាសលោកតា! អញ្ចឹងដូចជាឆ្នាំសត្វនឹងលោកតាកើតនៅក្នុងឆ្នាំអីដែរលោកតា?

ខ៖ ឆ្នាំសត្វនឹងតាកើតនៅក្នុងឆ្នាំ ខ្លា!

ក៖ អូ...ចាសលោកតា! ហើយទៅលោកតាមានទីលំនៅស្រុកកំណើតនៅឯណាដែរលោកតា?

ខ៖ ទីលំនៅស្រុកកំណើតនៅអឺ.....ភូមិត្រពាំងវែង ស្រុកកណ្ដាលស្ទឹង
ខេត្តកណ្ដាលយើងនឹងណាស់ចៅ! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា! ហើយទៅសព្វថ្ងៃនឹងលោកតាមានទីលំនៅៗឯណាដែររលោកតា?

ខ៖ សព្វថ្ងៃនឹងនៅផ្សារទឹកថ្លា អឺ....ភូមិផ្សារទឹកថ្លាសង្កត់ទឹកថ្លា!

ក៖ ចាសលោកតា! ហើយទៅទាក់ទងជាមួយនឹងសមាជិកគ្រួសារ
របស់លោកតាវិញលោកតាមានបងប្អូនប៉ុន្មានអ្នកដែរលោកតា?

ខ៖ បងប្អូនរបស់ខ្ញុំនឹងមាន....១០នាក់ទានណាស់ (មានសំលេងរំខានពីខាងក្រៅ)បាទ!

ក៖ ចាសលោកតា! ហើយទៅលោកតាគឺជាកូនទីប៉ុន្មាននៃគ្រួសារដែរលោកតា?

ខ៖ ខ្ញុំហ្អែស? ខ្ញុំជាកូនបងគេ!

ក៖ ចាសលោកតា!

ខ៖ បាទចៅ!

ក៖ ហើយទៅបងប្អូនរបស់លោកតាមានឈ្មោះអីខ្លះទៅលោកតា?

ខ៖ បាទឈ្មោះ អឺ.....រស់ រុន រស់ រ័ត្ន រស់អឺ....ស៊ីវណ្ណ រស់ រិទ្ធី បានប៉ុន្មានហើយចេះ?
បានបួនហើយប្រុសៗ (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកតា!

ខៈ ប្រុស....បាទ?

កៈ ចាសលោកតា!

ខៈ រស់ នៃ.....ចង់ភ្លេចទៅទៀតណាស់មើល! រស់ រុន រស់ រ័ត្ន រស់ រិទ្ធី រស់ រាយ នឹងហើយ រស់ រាយ!

កៈ រស់ រាយ ហ៎លោកតា? រស់ រាយ?

ខៈ បាទចៅ! ហើយទៅស្រីបីនាក់ បាទ!

កៈ អូ.....ចាសលោកតា!

ខៈ បាទ ហើយទៅស្រី៣នាក់ឈ្មោះ.....

គៈ អាឡូ....(មានសំលេងរបស់មនុស្សប្រុស)!

ខៈ ឈ្មោះ រស់ ផូ រស់ ផល!

កៈ ចាសលោកតា!

ខៈ រស់.....

កៈ ចាសលោកតា! អញ្ចឹងលោកតានៅចងចាំឈ្មោះតែប៉ុណ្ណឹងទេន៍លោកតា? (មានសំលេងរំខានពីខាងក្រៅ)!

ខៈ បាទ??

កៈ លោកតានៅចងចាំឈ្មោះតែប៉ុណ្ណឹងទេន៍លោកតា?

ខៈ បាទ! បាទ!

កៈ ចាសលោកតា! ហើយទៅលោកតាមាននៅចងចាំរឿងអីគេខ្លះដែលមានជាប់ទាក់ទងជាមួយនឹងបងប្អូនរបស់លោកតាណាស់លោកតា?

ខៈ បាទចៅ! ខ្ញុំចងចាំអូ...ច្រើនណាស់ទានអើយ (ក្រហែម) ព្រោះកាលពីដែលបងប្អូនខ្ញុំនឹងនៅតាកាលពីនឹងដូចថាវា(មានសំលេងរំខានពីខាងក្រៅ)

ជាមួយគ្នាវាដូចថាមានតែខ្ញុំមួយដែលជាបងរបស់គេដូចថាបន្ទាប់ពីបួសនឹងគ្រប់គ្រងបងប្អូននឹង
រកនេះរកនោះដើម្បីតែឆ្អែតតស៊ូជាម៉ែណាស់តស៊ូជាមួយនឹងម៉ែណាស់ជាមួយនឹងម៉ែជាមួយនឹងឪនឹង
ដើម្បីនឹងបានរកចិញ្ចឹមបងនឹងបានកើតរស់តាំងពីនឹងឯងមកយើងធ្វើស្រែធ្វើភ្លឺនឹងណាស់(មានសំលេងរំខានពីខាងក្រៅ) បាទ!

ក៖ ចាសលោកតា!
ចុះលោកតាពីនៅលោកតានៅក្មេងៗនឹងលោកតាចូលចិត្តធ្វើអ្វីគេខ្លះជាមួយនឹងពួកគាត់ណាស់លោកតា?

ខ៖ កាលនៅនឹងយើងនេះហ៎? (មានសំលេងរំខានពីខាងក្រៅ)!

ក៖ កាលពីលោកតានៅក្មេងៗ...

ខ៖ អូ...តា...

ក៖
ចូលចិត្តលេងអ្វីជាមួយនឹងពួកគាត់លេងឬក៏ចូលចិត្តធ្វើអ្វីជាមួយនឹងបងប្អូនរបស់លោកតាណាស់លោកតា?

ខ៖ នឹងហ៎ ចេះតែនឹកនៅក្នុងចិត្តថាអត់ទេ នៅខែធ្វើស្រែយើងនាំគ្នាធ្វើស្រែនឹងឯងទៅហើយនៅពេលខែចូលឆ្នាំក៏នាំគ្នាសប្បាយតែប៉ុណ្ណឹងបាទ(សើច) មានតែប៉ុណ្ណឹង!

ក៖ ចាសលោកតា! អញ្ចឹងអឺ...ចឹងដល់ពេលឥលូវនឹងពួកគាត់រស់នៅឯណាដែលលោកតា?

ខ៖ បាទពួកគាត់រស់នៅនឹងស្រុកកំណើត(មានសំលេងរំខានពីខាងក្រៅ) គាត់ធ្វើស្រែដែរនឹងឥលូវនឹង!

ក៖ ចាសលោកតា!

ខ៖ ហើយកូនៗនឹងខ្លះគេធ្វើការងារអីខ្លះហើយអញ្ចឹងណាស់!

ក៖ ចាសលោកតា!

ខ៖ នឹងហើយចៅ!

កៈ ហើយ....លោកតាចំពោះបងប្អូនហើយនឹងឪពុកម្តាយពួកគាត់មានឈ្មោះអីដែរលោកតា?

ខៈ គាត់ឈ្មោះ ឪពុករបស់ខ្ញុំនឹងគាត់ឈ្មោះ រស់ ហើយទៅនាមត្រកូលរបស់គាត់នឹង សំ រស់ (មានសំលេងរំខានពីខាងក្រៅ) ហើយទៅចំណែកម្តាយរបស់ខ្ញុំនឹងគាត់ឈ្មោះ ងៀម (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកតា!

ខៈ បាទនឹងហើយ!

កៈ ឥលូវនឹងពួកគាត់អាយុប៉ុន្មានឆ្នាំដែរហើយលោកតា?

ខៈ មកដល់.....អូ....ពួកគាត់ស្លាប់អស់ហើយទាន(មានសំលេងរំខានពីខាងក្រៅ) គាត់ស្លាប់កាលពីជំនាន់ចិតសិប អឺ....៦៩ (ឆ្នាំ១៩៧៩)!

កៈ អឹម....

ខៈ បាទចៅ! គាត់កាលនឹងពេលដែលគាត់ស្លាប់នឹងអាយុប៉ុន្មាននៅអាយុ ៥២ឆ្នាំនឹងចៅ! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកតា!
ចុះអឺ.....លោកតាមានដឹងថាពួកគាត់កើតនៅក្នុងឆ្នាំណាដែរឬទេទាំងឪពុកទាំងម្តាយរបស់លោកតាណាស់លោកតា?

ខៈ គាត់កើតនឹងអឹម...តាអត់បានកត់ទុកទេចៅយូរពេក(មានសំលេងរំខានពីខាងក្រៅ) បាទ!

គៈ
អឹម....ស្រេចតែម៉ងចៅបើសួរឪពុកកាលដែលគាត់កើតនឹងស្រេច(សំលេងរបស់លោកយាយ)!

ខៈ បាទ!

កៈ សូម្បីតែឆ្នាំកំណើតរបស់ពួកគាត់នឹងក៏លោកតាអត់ដឹងដែរន៍លោកតា?

ខៈ ឆ្នាំកំណើតដឹងតែ...ខ្ញុំដឹងតែថាឪពុករបស់ខ្ញុំគាត់ស្លាប់នៅក្នុងអាយុ ៥២ឆ្នាំ ហើយទៅម្តាយរបស់ខ្ញុំនោះគាត់ស្លាប់នៅក្នុងអាយុ ៥១ឆ្នាំ (មានសំលេងរំខានពីខាងក្រៅ)!

គៈ ពួកគាត់ខូចនៅកាលនឹងអស់ហើយ! (សំលេងរបស់លោកយាយ)!

កៈ អឺម....

ខៈ បាទពួកគាត់ខូចនៅកាលនឹងអស់ហើយចៅ(ស្លាប់)!

កៈ ចាសលោកតា! ហើយទៅលោតាដឹងថាពួកគាត់កើតនៅឯណាដែរឬទេលោកតា?

ខៈ គាត់កើតនៅនឹងស្រុកកំណើតនឹងម៉ងចៅ! កើតនៅនឹងភូមិត្រពាំងវែង ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាលនឹងម៉ង!

កៈ ទាំងពីរនឹងម៉ងលោកតាលោកយាយ?

ខៈ បាទទាំងពីរនាក់នឹងម៉ង!

កៈ ចាសលោកតា!

ខៈ កូនចៅអីនឹរស់នៅនឹងទាំងអស់.....

កៈ ចាសលោកតា!

ខៈ ហើយឥលូវនឹងនៅនឹងប្រាំនាក់នៅស្រុកកំណើតនឹង!

កៈ អឺម! ចាសលោកតា!
ហើយទៅលោកតាកាលពីមុននឹងឪពុកម្តាយរបស់លោកតានឹងពួកគាត់ធ្វើអីដើម្បីនឹងចិញ្ចឹមជីវិតរបស់លោកតាដែរលោកតា?

ខៈ បាទពួកគាត់ធ្វើស្រែ!

កៈ អឺម.....(មានសំលេងរំខានពីខាងក្រៅ)!

ខៈ រត់ស៊ីក្លូ រត់រ៉ឺម៉ក់ នៅកាលនឹងមិនទាន់មានម៉ូតូទេមានតែរ៉ឺម៉ក់(សើច)!

កៈ ចាសលោកតា!

ខៈ គាត់ជូនណាទៅគាត់ទៅរត់រ៉ឺម៉ក់ទៅ(សើច)
ហើយជូនណាទៅក៏ទៅធាក់ស៊ីក្លូនៅភ្នំពេញទៅ(មានសំលេងរំខានពីខាងក្រៅ)
គាត់មករត់នៅនឹងភ្នំពេញនឹង!

កៈ អឺម! ចាសលោកតា ហើយចុះអ្នកម្តាយរបស់លោកតាវិញ?

ខ៖ ម្ដាយរបស់ខ្ញុំនឹងគាត់មើលតែបាយចាននឆ្នាំងនៅនឹងផ្ទះនឹងមើលផ្ទះមើលសំប្បែងធ្វើស្រែធ្វើភ្លឺនឹង!

ក៖ អឺម! (មានសំលេងរំខានពីខាងក្រៅ) ហើយចុះពួកគាត់ជាមនុស្សបែបណាដែរលោកតា?

ខ៖ បាទមនុស្សគាត់ អត់ទេសុទ្ធអ្នកស្លូតចូលចិត្តធ្វើបុណ្យធ្វើទានណាស់បាទ! (មានសំលេងរំខានពីខាងក្រៅ) បាទ!

ក៖ អឺម! ...ចាសលោកតា! ហើយលោកតាអឺ....ចំពោះរឿងដែលលោកតាចងចាំជាមួយនឹងអ្នកម្ដាយហើយនឹងលោកឪពុករបស់លោកតានឹងមានអីគេខ្លះដែរលោកតា?

ខ៖ បាទក្មួយ! នៅក្នុងការចងចាំនៅក្នុងមួយជីវិតរបស់ខ្ញុំនឹងគឺខ្ញុំបានគោរពគាត់ជារហូតនឹងមកបាទ នៅពេលដែលខ្ញុំសឹកពីបួសវិញ (លាចាកសិក្ខាបទ) ខ្ញុំបានមកធ្វើនៅនឹងភ្នំពេញនេះបានប្រាក់ខែតិចតួចយកទៅជូនគាត់ហើយនៅកាលនឹងប្រាក់ខែបានតែមួយពាន់នឹងច្រើនណាស់អត់ដែលមានបាត់មួយរៀលនោះទេខ្ញុំយកទៅជូនគាត់ទាំងអស់ៗនឹងរាល់ខែបាទ!

ក៖ អឺម!

ខ៖ បាទកាលនឹងខ្ញុំបានឡើងមកធ្វើការនៅនឹងភ្នំពេញនឹងនៅអាយុ (មានសំលេងរំខានពីខាងក្រៅ) នៅពេលដែលខ្ញុំសឹកពីបួសមកវិញបាទ (លោកតាចូលធ្វើការបន្ទាប់ពីលាចាកសិក្ខាបទ)!

ក៖ ចាសលោកតា ហើយអញ្ចឹងពួកគាត់មានធ្លាប់ប្រាប់លោកតាថាកាលពីគាត់នៅក្មេងៗនឹងយ៉ាងម៉េចដែរឬទេលោកតាគាត់មានដែលប្រាប់លោកតាដែឬទេ? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បាទកាលពីនៅក្មេងៗនឹងគាត់មានបានប្រាប់តើ គាត់ប្រាប់ថាអោយខិតខំប្រឹងឡើងតែបន្តិចទៀតនឹងដល់ពុទ្ធទំនាយហើយគេថាគេនឹងធ្លាប់បានឆ្លងកាត់មកហើយដូចថា មានផ្លូវអត់មនុស្សដើរ មានជណ្ដើរអត់មនុស្សឡើងម៉េចទេ(សើច) ខ្ញុំវាអត់សូវដឹងច្បាស់ដែរគ្រាន់តែដឹងថាគេថានឹងវាត្រូវមែននឹងកាលពីជំនាន់ប៉ុលពត បាទ

(មានសំលេងរំខានពីខាងក្រៅ) បាទអត់ផ្លូវអត់អីនឹង ហើយផ្ទះអីនឹងរង្គើរអស់ហើយទាំងផ្ទះតូចទាំងផ្ទះធំនឹងរង្គើរអស់ហើយ បាទនឹងកាលពីជំនាន់ប៉ុលពតនឹងមកប៉ុន្មានបីខែ....បីឆ្នាំប្រាំបីខែមួយម្ភៃថ្ងៃនឹងបាទ (មានសំលេងរំខានពីខាងក្រៅ) ហើយតាតាអីនឹង(សំលេងរបស់តាតាសើច) អូ....មិនធម្មតាទេមនុស្សសុទ្ធមានបុណ្យហើយនៅដល់ចាស់ជំនាស់ៗនឹងដែលបានរស់មកដល់សព្វថ្ងៃនឹងណាស់ចៅ!

ក៖ ចាសលោកតា!

ខ៖ ហើយបើនិយាយប្រាប់កូននឹងអត់ជឿរទេ បើថាស៊ីបបរវិញដប់កំប៉ុងនឹងគ្នាមួយរយនាក់ដែលគេថាដើរទាក់តែកញ្រាំងដួលណាស់ចៅ នៅតែស្បែកហើយនឹងឆ្អឹងទេកាលពីចៅ (មានសំលេងរំខានពីខាងក្រៅ)!

គ៖ គេដួសមួយឆ្នាំងមកនឹងគេទឹក ទឹកនឹងដូចថាសិស្សសាលារៀនអញ្ចឹងគេដាក់កណ្តាលមកដួសមកហើយយើងយកចានទៅដួសមកហូបនឹង....(មានសំលេងរបស់មនុស្សស្រី)!

ខ៖ នឹងហើយអានឹងហើយ(សើច)!

គ៖ ខ្ញុំកើតទាន់តើពុកខ្ញុំចងក្បែរពោងខ្ញុំដឹងច្បាស់ណាស់! (សំលេងរបស់មនុស្សស្រី)!

ខ៖ នឹងហើយអ្នកដែលអាយុ៥០ឆ្នាំឡើងនឹងគឺទាន់ហើយបាទ!

ក៖ ចាសលោកតា!

គ៖ ខ្ញុំអាយុ៥០ឆ្នាំជាងហើយខ្ញុំទាន់តើ (សំលេងរបស់មនុស្សស្រី)!

ខ៖ បាទបើអាយុត្រឹមតែ៣០ឆ្នាំជាងនឹងគឺគ្នាអត់ទាន់ទេនឹងអត់ដឹងទេ!

ក៖ ចាសលោកតា!

គ៖ តែ៤០ឆ្នាំចុះនឹងក៏អត់មានដែរ(សំលេងរបស់លោកយាយ)!

ខ៖ អឺ....៤០ឆ្នាំចុះនឹងក៏អត់ទាន់ដែរ!

ក៖ (សើច)!

ខ៖ បាទៗនឹងហើយ!

កៈ ចាសលោកតា! ហើយអញ្ចឹងលោកតា....

ខៈ បាទៗ....

កៈ ទាក់ទងជាមួយនឹងជីដូនជីតារបស់លោកតាវិញតើពួកគាត់មានឈ្មោះអីខ្លះដែរលោកតា?

ខៈ បាទ នែ...ជីដូនជីតារបស់ខ្ញុំនឹងគាត់ឈ្មោះ សំ...លោកតាសំ
បាទហើយទៅលោកយាយរបស់ខ្ញុំនឹងគាត់ឈ្មោះ លោកយាយ ពង្ស
ហើយទៅយាយនៅខាងម្ដាយនោះឈ្មោះ តាសួង ហើយនឹង លោកយាយប៉ូ
បាទនឹងឈ្មោះជីដូនជីតារបស់ខ្ញុំ!

កៈ ចាសលោកតា!

ខៈ បាទចៅ!

កៈ អូ....ហើយលោកតានៅចងចាំបានល្អណាស់!

ខៈ បាទៗ!

កៈ
ហើយទៅលោកតាកាលនឹងគាត់កើតនៅក្នុងឆ្នាំណាដែរលោកតាមានដឹងដែរឬទេលោកតា?

ខៈ អូ....(សើច) អត់មានទេ
អត់មានបានកត់ទុកទេចៅព្រោះកាលនៅនឹងជំនាន់ប៉ុលពតនឹងសៀវភៅចោលខ្ទេចខ្ទីអស់
ហើយគ្មានបានទុកដាក់អីទេ(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចុះគាត់កើតនៅកន្លែងណាដែរលោកតា?

គៈ ចុះយើងគិតទៅគាត់ស្លាប់នៅក្នុងអាយុ៥២ឆ្នាំ
ហើយទៅយើងគាត់កើតនៅក្នុងឆ្នាំប៉ុន្មានយើងគិតទៅដឹងហើយ! (សំលេងរបស់មនុស្សស្រី)!

ខៈ បាទនៅនឹងភូមិត្រពាំងវែង ស្រុកកណ្ដាលស្ទឹងនឹង!

កៈ អឺម!

ខៈ បាទៗ!

កៈ ចាសលោកតា!
ហើយអឺ....លោកតាមានចងចាំរឿងអីគេខ្លះពីលោកតាលោកយាយរបស់លោកតាណាស់លោកតា?

ខៈ អូ...ខ្ញុំមានការចេងចាំនឹងច្រើនដែរបាទ
ខ្ញុំធ្លាប់បានឆ្លងកាត់របបនឹងបីរបបមកហើយតាំងពីជំនាន់ឥស្សរៈមកណាស់កូនណាស់!

កៈ ចាសលោកតា!

ខៈ អឺ...

គៈ មានបារាំង...(សំលេងរបស់លោកយាយ)!

ខៈ អឺម! ជំនាន់បារាំង អុំនេះបានឆ្លងកាត់ច្រើនណាស់មកទាមទារឯករាជ្យជាមួយនឹងសម្តេចឪសឹកពីបួសមកវិញធ្វើកាំភ្លើងមួយដើម(សើច) កាំភ្លើងឈើណាស់(សើច)....

គៈ ចុះបើជានារីក្លាហានណាស់!

ខៈ មកដេកនៅនឹងកណ្តាលនឹងតស៊ូដេកនៅនឹង!

គៈ កាំភ្លើងមានទៅមានកាំភ្លើងល្អស្អី(សំលេងរបស់លោកយាយ)!

ឃៈ
អូ....រឿងរបស់យាយនឹងខ្ញុំឧស្សាហ៍លឺម្តាយរបស់ខ្ញុំនិយាយដែរតើ(សំលេងរបស់មនុស្សស្រី)!

ខៈ (សើច)!

ឃៈ នារីៗដែលដើរធ្វើគេហៅយុវវាន់ៗនឹងហី?

ខៈ អើ! យុវវ៉ានៗនឹង នឹងហើយគេយុវនារីនឹងនិយាយឡើងស្រក់ទឹកភ្នែកបាន!

ឃៈ ខ្ញុំឃើញតែមកហាត់ក្រាបលូនៗនឹង! (សំលេងរបស់មនុស្សស្រី)!

ខៈ បាទ(មានសំលេងរំខានពីខាងក្រៅ)!

គៈ កាលនឹងស្របាលនឹងណាស់ចូលធ្វើនារីក្លាហានដេញបារាំងទៅស្រុកវិញនឹង!
(សំលេលងរបស់លោកយាយ)!

ខ៖ បាទបានក្រោយមកនឹងបានៗទទូលឯករាជ្យជាប់ប៉ុន្មានទេនេះកាលនឹងសម្តេចឪ ៣០ឆ្នាំ ៤០ឆ្នាំ ដែរហើ?

គ៖ អឺ!

ក៖ អឺម!

ខ៖ បានសំបូរសប្បាយអញ្ចឹងទៅ
បានមកដល់ជំនាន់លន់នលនេះបានគេធ្វើរដ្ឋប្រហារនឹងម្តងទៀតនឹងបានធ្លាក់សម្តេចនឹង!

គ៖ គេធ្វើរដ្ឋប្រហារទំលាក់សម្តេចឪនឹង! (សំលេងរបស់លោកយាយ)!

ឃ៖ កាលពីជំនាន់លន់នល ធ្វើរដ្ឋប្រហារនឹងឯងទៅបានពួកអាយួន....(ស្តាប់អត់បាន) វាចូលមកនៅនឹងស្រុករបស់យើង!

ខ៖ នឹងជំនាន់លន់នលគេធ្វើប្រហារនឹងទៅបានចូលទៅធ្វើជាទាហាននឹងគេឯងទៅ ទៅខ្ញុំក៏ធ្វើជាទាហាននឹងដោយសារតែឃើញគេចាប់លិចចាប់កើតក៏ចូលទៅធ្វើជាទាហាននឹង គេឯងទៅ(សើច)!

ក៖ ចាសលោកតា!

ខ៖
បាទបានចប់ពីទាហានចប់ពីលន់នលហើយបានមកដល់ត្រឹមជំនាន់ប៉ុលពតនោះហ៎គេប្រើយើងនឹងមិនបាច់ទេ ដើរ....ដើរទាក់ជញ្ជាំងដួលណាស់កូន!

ក៖ ចាសលោកតា!

គ៖ បើនិយាយទៅក្មេងឥលូវនឹងមិនជឿរទេពុក
កាលពីជំនាន់ប៉ុលពតគេជ្រលក់អាចម៍សុទ្ធតែកង្កួរអោយស្ទូងនោះ
ប្រើអោយយើងឡើងស្ទូងកណ្តាលអាធ្រាតនឹងយប់ឡើងនឹងឡើងទៅស្ទូងហើយ(សំលេងរបស់មនុស្សស្រី)!

ខ៖ បាទៗនឹងហើយ!

គ៖ ហើយបើយើងនិយាយទៅក្មេងឥលូវនឹងគេមិនជឿរទេ! (សំលេងរបស់មនុស្សស្រី)!

ខ៖ បាទ ចុះបើគ្នាវាអត់ទាន់ជំនាន់នឹងអញ្ចឹងគ្នាអត់ជឿរទេ
ដូចលឺថាយើងហូបបបរកន្លះវែកអីនឹងគ្នាអត់ជឿរទេបាទ បើគ្នាមិនទាន់ធ្វើម៉េចនឹងជឿរនោះ!

គ៖ ក្មេងឥលូវនឹងនិយាយទៅគេមិនជឿរទេ
កាលពីជំនាន់ប៉ុលពតនឹងចានឆ្នាំងគេប្រមូលយកដាក់រួមអស់ហើយ
អោយតែដល់ម៉ោងបាយគេវៃជួងហើយ! (សំលេងរបស់មនុស្សស្រី)!

ខ៖ នឹងហើយទាល់តែក្មេងជំនាន់នឹងបានដឹងបាទ!

គ៖ នឹងហើយអោយតែដល់ម៉ោងបាយនឹងគេវៃជួងហើយដល់ម៉ោងបាយបបរ
ហើយទៅមួយឆ្នាំបានគេដាំបាយអោយហូបជប់លៀងម្តងនឹងអរណាស់ទៅហើយ!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖ ចាសលោកតា!
អញ្ចឹងទាក់ទងជាមួយនឹងក្រុមគ្រួសាររបស់លោកតាវិញតើក្រុមគ្រួសាររបស់លោកតារស់នៅខាងខេត្តនឹងរយះពេលប៉ុន្មានឆ្នាំដែរលោកតា?

ខ៖ បាទ គ្រួសារនៅខេត្តឯណោះមើលតាំងពីបែកប៉ុលពតជំនាន់៧៩មក (ឆ្នាំ ១៩៧៩)
មកនៅសល់បួននាក់ ស្រីបីនាក់ នឹងប្រុសមួយនាក់
នឹងគ្នាប៉ុន្មានមើលដប់នាក់ណាស់ថៅនៅសល់តែប្រាំនាក់មកវិញទេ!

ក៖ អូ.....ចាសលោកតា! អញ្ចឹងតាំងពីជំនាន់៧៩នឹង (ឆ្នាំ ១៩៧៩)
នឹងមកគឺពួកគាត់រស់នៅនឹងឯនឹងរហូតមកន៏លោកតា?

ខ៖ បាទឆ្នាំ ១៩៧៩!

ក៖ ហើយចំពោះ.....

ខ៖ ហើយទៅពួកនោះប្រហែលជាស្លាប់នៅក្នុងជំនាន់ប៉ុលពតអស់ហើយបាទ!

ក៖ ចាសលោកតា!
ហើយចំពោះសាច់ញាតិរបស់តាវិញលោកតាមានសាច់ញាតិនៅក្រៅប្រទេសដែរឬទេលោកតា?

ខ៖ បាទចំពោះសាច់ញាតិនៅក្រៅប្រទេសនឹងដូចជាអត់មានផងខ្ញុំ (មានសំលេងរំខានពីខាងក្រៅ)!

ក៖ ចាសលោកតា! ហើយចុះការរៀបអាពាហ៍ពិពាហ៍វិញតើលោកតាបានរៀបការជាមួយនឹងលោកយាយដែលត្រូវជាប្រពន្ធរបស់លោកតានឹងណាស់...

ខ៖ បាទៗ!

ក៖ ចាសលោកតាលោកយាយគាត់មានឈ្មោះអីដែរលោកតា?

ខ៖ បាទ គាត់ឈ្មោះ ញឹម សុខ ទានណាស់!

ក៖ ចាសលោកតា! (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បាទគាត់ភរិយាយរបស់ខ្ញុំនឹង!

ក៖ ហើយទៅលោកតារៀបការនៅពេលណាដែរលោកតា?

ខ៖ រៀបការនៅក្នុងឆ្នាំ ១៩០០.....ប៉ុន្មាននោះទេក្មួយលោកអើយតាចង់ភ្លេចអស់បាត់ហើយអត់ចាំទេក្មួយ!

ក៖ ឆ្នាំ....នៅក្រោយជំនាន់ប៉ុលពតឬក៏មុនលោកតា?

ខ៖ បាទ?

ក៖ នៅក្រោយប៉ុលពតឬក៏មុន?

ខ៖ អត់ទេនៅមុនប៉ុលពត!

ក៖ អូ....នៅមុនជំនាន់ប៉ុលពត!

ខ៖ នៅជំនាន់សម្តេចឪឯណោះ!

ក៖ អូ....ចាសលោកតា!

ខ៖ បាទ!

ក៖ អញ្ចឹងលោកតាអាពាហ៍ពិពាហ៍នឹងរៀបចំឡើងដោយឪពុកម្តាយឬក៏លោកតាស្រលាញ់គ្នា?

ខ៖ អត់ទេ ឪពុកម្ដាយរបស់ខ្ញុំគាត់ចូលស្ដីដណ្ដឹងធ្វើផ្ទះធ្វើអីនឹងស្រួលបួលណាស់កូន
ធ្វើកូនថៅបាទកាលពីជំនាន់នឹងណាស់!

ក៖ ចាសលោកតា!

ខ៖ បាទ ទាល់តែមានផ្ទះបានគេអោយកូនអញ្ចឹងហើយយើងទាល់តែធ្វើផ្ទះអោយគេ(សើច)!

គ៖ នឹងហើយ(សំលេងពីខាងក្រៅ)!

ក៖ (សើច)!

ខ៖ (សើច) តឹងណាស់កាលនឹងទៅបំរើគេនឹងកាំបិតត្រឹមត្រូវណាស់
បើធ្វើតែផ្លិកផ្លក់ដូចឥលូវនឹងគឺអត់បានទេ!

ក៖ ចាសលោកតា!

ខ៖ គាត់ប្រកែប្រកាន់ណាស់ចាស់ៗពីដើមនឹង!

ក៖ ចាសលោកតា!

ខ៖ គាត់ត្រឹមត្រូវណាស់ហើយគោរពតាមប្រពៃណីរបស់ខ្មែរណាស់បាទ
(មានសំលេងរំខានពីខាងក្រៅ)
តែអ្នកណាស៊ីផឹកប្រឡាំប្រកូវអីនឹងគាត់មិនលើកកូនក្រមុំអោយទេ!

ក៖ ចាសលោកតា!

ខ៖ បាទ! មិនដូចឥលូវនឹងទេបាទ!

ក៖ (សើច)! លោកតាអញ្ចឹងកាលនឹងគេមានបង្គាប់ថ្លៃជំនូនទេលោកតា?

ខ៖ បាទបង្គាប់ថ្លៃជំនូននឹងគាត់បង្គាប់ផ្ទះនឹងតែម្ដងណាស់នាង!

ក៖ បង្គាប់ផ្ទះហ៎?

ខ៖ នឹងហើយអោយធ្វើផ្ទះអោយម៉ង(សើច)!

ក៖ នឹងជាថ្លៃជំនូនហើយន៍លោកតា?

ខ៖ (សើច) ថ្លៃទឹកដោះធ្វើផ្ទះនឹងអោយរួចហើយបានគេរៀបការ!

កៈ អឺម!

ខៈ បាទ!

កៈ ប៉ុន្មានឆ្នាំទៅលោកតាបានធ្វើហើយ?

ខៈ អូ...ធ្វើផ្ទះប្រហែលមួយឆ្នាំដែរនឹង!

កៈ (សើច) យូរដែរទម្រាំតែធ្វើហើយន៏លោកតា?

ខៈ (សើច)!

គៈ ជំនាន់នោះកូនប្រុសទៅធ្វើជាប់បាវបំរើគេបីឆ្នាំទើបបានគេលើកកូនក្រមុំអោយ! (មានសំលេងរបស់មនុស្សស្រី)!

ខៈ អើ....ទៅធ្វើបាវគេនឹងបាន!

គៈ បីខែទៅម៉ែឪខាងប្រុសនឹងត្រូវយកជំនូនទៅខាងស្រីម្តង! (សំលេងរបស់មនុស្សស្រី)!

ខៈ (សើច)!

កៈ ចុះកាលនឹងលោកតាមានចិត្តស្រលាញ់ខាងលោកយាយខ្លាំងដែរឬទេលោកតាកាលនឹង?

ខៈ
បើតាមខ្ញុំកាលនឹងខ្ញុំអត់សូវស្រលាញ់ទេកាលនឹងប៉ុន្តែខ្ញុំតាមឪពុកតាមម្តាយខ្ញុំទៅស្រលាញ់គេឯណាណោះផ្សេងទេសមាទោស (សើច)!

កៈ (សើច)!

ខៈ តែមកស្រលាញ់យាយនេះអត់ដឹងខ្លួនទេណាស់!

គៈ ចាស!

ខៈ ដល់ពេលតែឪពុកម្តាយរបស់ខ្ញុំនឹងនាំទៅក៏ជាប់ចិត្តក៏ស្រលាញ់យាយនឹងម៉ងទៅ!

គៈ ទៅបណ្តោយ (សើច)  (សំលេងរបស់លោកយាយ)!

ខៈ បាទ (សើច)!

កៈ ចាស (សើច)!

គ៖ ចាស់ពីដើមអញ្ចឹងណាស់!

ខ៖ យើងដូចថាតាមឪពុកតាមម៉ែណាស់!

គ៖ តែម៉ែឪត្រូវចិត្តត្រូវហើយ!

ខ៖ នឹងហើយអោយតែម៉ែឪត្រូវចិត្តនឹងហើយ!

ក៖ (សើច) ចាសលោកតា! អញ្ចឹងចុះតើលោកតាអាចប្រាប់ចៅបានទេថា....

ខ៖ បាទ??

ក៖
កាលពីមុននឹងលោកតាបានជួបនឹងលោកយាយដំបូងនៅអឺ...យ៉ាងម៉េចដែរលោកតាកាលនឹង
?

ខ៖ អូ...កាលជួបមុនដំបូងយើងវាកំសត់កម្រដែរនឹងចៅអើយ
អោយនិយាយរឿងអញ្ចឹងៗនឹងស្រេចបាត់ហើយ កវែកកន្ត្រាំងពិបាកណាស់កូនមួយ កូនពីរនេះ
ហើយតាកាលនឹងធ្វើស្រែពិបាកណាស់បាទ (មានសំលេងរំខានពីខាងក្រៅ)
ធ្វើស្រែនេះធ្វើតែខ្ញុំរួចបងៗនឹងទៅធ្វើជាទាហាននឹងអស់ទៅហើយទៅនៅស្រែនោះប៉ុន្មានហិច
តានឹងខ្ញុំធ្វើទាំងអស់!

ក៖ អឹម!

ខ៖ បាទពីរនាក់ប្តីប្រពន្ធនឹងឯង
ហើយជំនាន់នោះធ្វើស្រូវធ្វើអីនឹងបានហើយអត់មានលក់ស្រូវទិញឡានទិញម៉ូតូដូចសម័យគេ
ឥលូវនេះទេទៅទិញតែដី ទិញដីទុកធ្វើស្រែ(សើច) !

ក៖ (សើច)!

គ៖ អ្នកស្រែធ្វើតែស្រែនឹងហើយ! (សំលេងរបស់លោកយាយ)!

ខ៖ បាទហើយទៅស្រូវវិញពេញៗជង្រុក អើ!
អត់មានគេប្រាប់ថាអូ...ទិញម៉ូតូទិញអីជិះទេអត់មានទេ
ហើយអានេះទិញប្រើហើយនឹងខ្លាចថាអត់មានលុយចាក់សាំងទៀតណាស់ (សើច)!

គ៖ ចាស!

ខ៖ ប៉ុន្តែអញ្ចេកដូចថាស្រូវពូជអីនឹងមានពេញៗនឹងជង្រុកមានមិនដែលខ្វះទេណាស់ជំនាន់នឹងណាស់!

គ៖ ហូបខ្ចូបទៅខ្ចូបមក!(សំលេងរបស់លោកយាយ)!

ខ៖ បាទហូបខ្ចូបទៅខ្ចូបមក!

គ៖ មិនដែលទៅលក់បានមួយគីឡូទេ (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ហូបបានតែមួយឆ្នាំទេ ហើយទៅមួយឆ្នាំនឹងហូបអត់អស់លក់ព្រោះអីយើងនៅតែឯងបងប្អូនគេឡើងមកធ្វើជាទាហានអស់ហើយគេមានប្រាក់ខែស៊ី ហើយចេះតែជូនណាទៅគេមកលេងអញ្ចឹងទៅកិតអង្ករអោយបងប្អូននឹងធ្វើទាហានធ្វើអីនឹងបាទ!

ក៖ អឺម....ចាសលោកតា!

ខ៖ បាទចៅ!

ក៖ អញ្ចឹងទាក់ទងជាមួយនឹងវិញណាសលោកតា តើលោកតាអាចនឹងចេះអាននឹងសរសេរភាសាខ្មែរនឹងបានល្អដែរឬទេលោកតា?

ខ៖ បាទៗ អាចអានហើយនឹងសរសេរបានបន្តិចបន្តួច!

ក៖ អឺម! លោកតាហើយទៅលោកតាចេះភាសាក្រៅពីភាសាខ្មែររបស់យើងដែរឬទេលោកតា?

ខ៖ អត់ អឺម....ចេះតែវាអត់ច្បាស់នោះទេ ចេះនឹងបន្តិចបន្តួចៗនឹងបារាំងនឹងចេះបានបន្តិចទៅយួននឹងបន្តិចទៅ (សើច) គ្រាន់តែបានតែចេះប៉ុន្តែអត់ទៅចេះអក្សរនឹងគេទេណាស់!

គ៖ ចាស (សំលេងរបស់លោកយាយ)!

ខ៖ បើភាសាបារាំងនឹងរៀនដែរ តែដល់ជំនាន់សង្គ្រាមនឹងក៏ឈប់រៀនទៅ!

គ៖ ចុះបើស្រុកគេក្លាយទៅជាអញ្ចឹងទៅ! (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បាទដល់តែស្រុកទេសរបស់គេក្លាយទៅជាអញ្ចឹងទៅចប់!

ក៖ តែកាលនឹងលោកតាអាចនឹងចេះអានបានដែរឬទេលោកតា?

ខ៖ បាទ??

ក៖ ចេះអានចេះសរសេរដែរឬទេភាសាបារាំងជំនាន់នឹង?

ខ៖ អត់ទេៗ!

ក៖ ចាសលោកតា! ហើយទៅលោកតារៀនបានត្រឹមថ្នាក់ទីប៉ុន្មានដែរលោកតា?

ខ៖ ខ្ញុំរៀនបានកាលនឹងបានត្រឹមថ្នាក់ទីប្រាំបួន ហើយយើងសាកគិតមើលទៅមើលថ្នាក់ទីប្រាំបួនកាលនឹង (មានសំលេងរំខានពីខាងក្រៅ) តាំងពីថ្នាក់គេរាប់ចុះទៅក្រោមវិញមើល ១២ ១១ អឺ....១១ ១២ រួចខ្ញុំរៀនដល់ត្រឹមថ្នាក់ទីប្រាំបួនបានប៉ុន្មានបីថ្នាក់ ប្រាំថ្នាក់ដែរណាស់!

ក៖ អឹម! អញ្ចឹងលោកតាបញ្ចប់ត្រឹមថ្នាក់ទីប្រាំបួន?

ខ៖ ហើយមកដល់ឥលូវនេះគេរាប់បញ្ច្រាសមកវិញ...បាទ!

ក៖ កាលនឹងម៉េចក៏លោកតា.....(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ កាលនឹងឯងទៅបួសបានតែឈប់រៀននឹងនោះ ទៅបួស!

ក៖ ចាសលោកតា!

ខ៖ បួសហើយបានទៀត រៀនធម៌រៀនអារ្យនឹងណាស់!

គ៖ ចាស! (សំលេងរបស់លោកយាយ)!

ក៖ ចាសលោកតា!

ខ៖ បាទ!!

ក៖ ហើយសាលាលោកតារៀននឹងនៅឯណាដែរលោកតា?

ខ៖ បាទសាលានៅខាងឯស្រុកកំណើតនឹងដែរនៅខាងភូមិកន្ទួត! (មានសំលេងរំខានពីខាងក្រៅ)!

ក៖ មានឈ្មោះអីដែសាលានឹងលោកតា?

ខ៖ បាទសាលាភូមិកន្លួតបាទ!

គ៖ ដាក់បានរហូតទៅដល់ពីរស្រះឯណោះ! (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ អឹម! សាលាកាលនឹងភ្លេចឈ្មោះបាត់ទៅហើយអនុវិទ្យាល័យនឹង!

ក៖ អឹម!

ខ៖ ភ្លេចអស់ហើយ!

ក៖ ចុះលោកតាមានមិត្តភក្តិស្និទ្ធស្នាលរហូតមកដល់ឥលូវដែរឬទេ?

ខ៖ អូ....មិត្តភក្តិស្និទ្ធស្នាលនឹងអ្នកខ្លះគេទៅអាមេរិចខ្លះគេទៅអស់ទៅបែគ្នាអស់ហើយចៅអើយ!

ក៖ អូ.....

ខ៖ បាទ!!

ក៖ ហើយទៅគាត់មានឈ្មោះអីខ្លះទៅលោកតា?

ខ៖ បានមួយនឹងគ្រូសកលវិទ្យាល័យ ហើយមួយទៀតនឹងអានេះ....អា វេ អានឹងឈ្មោះរបស់វានឹងពិបាកនឹងចាំណាស់!

ក៖ ចាសលោកតា! អញ្ចឹងលោកតាមានចងចាំនូវរឿងរ៉ាវអីគេខ្លះជាមួយនឹងមិត្តភក្តិរបស់លោកតាកាលពីសម័យនឹងណាស់លោកតា?

ខ៖ បានរួចកាលនឹងឯងមានការចងចាំដូចថាយើងដើរលេងជាមួយនឹងគ្នានឹងឯងទៅហើយអឺ....ការរៀនសូត្រនឹងយើងអត់ចេះអីនឹងត្រូវការពិភាក្សាគ្នាអញ្ចឹងទៅខំប្រឹងយ៉ាងម៉េចអោយបានតែធ្វើលំហាត់នឹងចេញដាស់តឿនគេតែប៉ុណ្ណឹងទេ!

ក៖ ចាសលោកតា!

ខ៖ កុំដើរផ្តេសផ្តាសអីនឹង យើងជួយដាស់តឿនគេតែប៉ុណ្ណឹងណាស់!

ក៖ ចាសលោកតា!

ខ៖
កុំដើរទៅផ្លូវខុសយើងធ្វើម៉េចបើកើតមកតាមសង្គមតាមអឺ...ប្រពៃណីរបស់ខ្មែរយើងនឹងគឺយើងមានតែជួយលើកស្ទួយគ្រួសារហើយនឹងប្រទេសជាតិរបស់យើង!

ក៖ ចាសលោកតា!

ខ៖ បាទមានតែប៉ុណ្ណឹង!

ក៖ ចាសលោកតា! លោកតាធ្លាប់ធ្វើស្រែដែរឬទេលោកតា? (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ បាទ??

ក៖ លោកតាមានដែលធ្លាប់ធ្វើស្រែចំការដែរឬទេ?

ខ៖ បាទធ្លាប់ធ្វើស្រែរាប់ឆ្នាំនឹងមិនឈ្នុះនឹងធ្វើទេ បាទ!

ក៖ អញ្ចឹងមានន័យថាឪពុកម្តាយរបស់លោកតាគឺជាកសិករ?

ខ៖ បាទ ពួកគាត់គឺជាកសិករបាទ!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖ អញ្ចឹងនៅក្នុងជីវិតរបស់លោកតានឹងតើលោកតាធ្លាប់បានធ្វើការងារអ្វីខ្លះដែរលោកតា?

ខ៖ បាទខ្ញុំមកនៅនឹងគ្រាន់តែអត់មានធ្វើការងារអីនោះទេកាលពីមកមុនដំបូងនឹងខ្ញុំមកធ្វើជាកម្មកររបស់គេនៅភ្នំ.....ភ្នំពេញនឹងឯងណាស់ ហើយក្រោយពីនឹងឯងមកបានត្រឡប់ពីភ្នំពេញនឹងមកធ្វើជាទាហាននៅក្នុងឆ្នាំ ៧០នេះ (ឆ្នាំ១៩៧០) នៅជំនាន់លន់នលនេះបាទ បានធ្វើទាហាននឹងហើយបានបែកពីធ្វើទាហាន៧៩ (ឆ្នាំ ១៩៧៩) នឹងឯងមកបានមកចូលយើងចូលដល់ប៉ុលពតនឹងឈប់ហើយ!

ក៖ ចាសលោកតា!

ខ៖ គេជំលៀសទៅលាក់ការណ៍អត់ប្រាប់ថាធ្លាប់ធ្វើជាទាហានទេកាលទេកាលនឹងប្រាប់តែគេស៊ីវិលទេ!

គ៖ ដើរសំភាសន៏តែចាស់ៗហ្អែស? (សំលេងរបស់មនុស្សស្រី)!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖
លោកតាអញ្ចឹងកាលពីក្មេងរហូតមកដល់ឥលូវនឹងជីវិតរបស់លោកតានឹងមានការផ្លាស់ប្តូរយ៉ាងណាខ្លះដែរលោកតា?

ខ៖ បាទ និយាយពីរឿងដែលផ្លាស់ប្តូរនឹងគឺវាផ្លាស់ប្តូរទៅតាមសង្គមរបស់គេនាងអើយ បើសង្គមតាំងពីជំនាន់ឥស្សរៈនឹងមកកាលនឹងជីវិតរបស់យើងវាក៏ល្វឹងជូរចត់ដែរនឹងណាស់បាទ ហើយមកឆ្លងកាត់នៅសង្គមប៉ុលពតនេះបានលំបាកមែនទែននឹងនឹកគិតតែថាមិនបានវិលមកឃើញភ្នំពេញវិញទេទានអើយ
បាទសុទ្ធឆ្អឹងដែកស្បែកស្គាន់នឹងហើយលោកយាយលោកតាជំនាន់ៗនេះនោះ
នៅជនបទបាទ
ហើយកាលនឹងគេអោយយើងហូបបបរបាទហើយបើគ្នាដប់នាក់អី...អឺ....អង្ករដប់កំប៉ុងអីបបរអោយគ្នាមួយនាក់ហូបអីអញ្ចឹងបបរអោយយើងហូបនឹងហើយទៅដើរបូតស្លឹកអីៗនឹងយកទៅដាក់លាយនឹងទៅហូបលាយជាមួយនឹងបបរអីនឹងទៅគ្រាន់បានឆ្អែតៗតឹងៗពោះនឹងឯងទៅណាស់ចៅ(មានសំលេងរំខានពីខាងក្រៅ)!

គ៖ អង្ករដប់កំប៉ុងនឹងបានចង់មួយរយនាក់ហើយ(សំលេងរបស់មនុស្សស្រី)!

ខ៖ បាទយាយ!
យើងវាកំសត់កម្ររកជំនាន់ណាអោយដូចទៅនឹងជំនាន់នឹងគ្មានទេជំនាន់នោះពិបាកណាស់គេមិនអោយយើងហូបឆ្អែតទេ!

ក៖ អ៊ឹម!

ខ៖ បាទយើងធ្វើបានដែរក៏ប៉ុន្តែគេមិនអោយយើងស៊ី ហើយយើងនឹងធ្វើម៉េចគេយើងមិនហ៊ានទៅសុំគេមកទេ!

ឃ៖ ស្រូវពេញៗជង្រុក! (សំលេងរបស់មនុស្សស្រី)!

ខ៖ បាទនឹងហើយស្រូវបានពេញៗជង្រុក!

គ៖ ស្រូវប្រមូលផលបានធ្វើឃ្លាំងដាក់ទៅ!

ខ៖ បានធ្វើឃ្លាំងដាក់នឹងទៅ ហើយទៅមិនដឹងថាគេយកទៅណា!

គ៖ កងនារីដាក់មុខ(សំលេងរបស់មនុស្សស្រី)!

ក៖ ចាសលោកតា!

គ៖ អ្នកដែលមានកូននឹងទុកអោយយាយៗនឹងមើលទៅ ហើយទៅម៉ែឪទៅស្ទូងស្រូវបាត់ៗទៅមិនបាននៅមើលថៃកូនអីទេ!

ខ៖ បាទអញ្ចឹងបានថា! អញ្ចឹងហើយបានតែនាំគ្នាបន់នឹងអោយតែអ្នកណារំដោះអោយរួចមកក៏បានដែរ អោយតែយើងបានរួចរស់ជីវិតឡើងវិញនឹងត្រេចអរណាស់ អញ្ចឹងបានថានឹកទៅដល់គុណរបស់សម្តេចហ៊ុនសែន (មានសំលេងរំខានពីខាងក្រៅ) លោកតា ជា ស៊ីមអីទាំងអស់គ្នាជំនាន់នឹងគាត់បានមកជួយរំដោះប្រទេសជាតិបានមករំដោះប្រជាជនអីនឹង បានយើងមានការត្រេកអរណាស់បានដូចបានកើតមកម្តងទៀតអញ្ចឹងណាស់នឹងយាយៗពួក គាត់ចំណាំតែថាបានកើតមកម្តងទៀតហើយ(សើច)!

ក៖ (សើច)!

ខ៖ បាទនឹងហើយ!

ក៖ ចាសលោកតា! ហើយទៅលោកតាចូលចិត្តម្ហូបអីគេដែរតាំងពីក្មេងរហូតមកដល់ឥលូវនឹងណាស់លោកតា?

ខ៖ នេះម្ហូបធម្មតាស្លរម្ជូរស្លរប្រហើរអីនឹង(សើច)!

គ៖ ប្រហុកអីនឹង!(មានសំលេងរំខានពីខាងក្រៅ)!

ខ៖ (សើច) តែប៉ុណ្ណឹងប្រហុក!

ក៖ (សើច)!

ខ៖ បាទ!

គ៖ មិនដឹងថាសម្លរអីគេទេ! (សំលេងរបស់លោកយាយ)!

ខ៖ បាទនឹងហើយ!

កៈ ចាសលោកតា!

គៈ មិនដែលស្គាល់សាច់ជ្រូកសាច់សោយអីទេកើតមកមួយជាតិនេះនោះ!

ខៈ បាទៗ!

កៈ (សើច)!

គៈ មានតែសម្លរប្រហើរ ម្ជូរ កកូរអីនឹងឯង(សំលេងរបស់លោកយាយ)!

ខៈ ហើយមានតែត្រីឆ្អើរនឹងស្លប្រហើរ ហើយទៅយើងមានដាំបន្លែដែលនៅក្បែរៗផ្ទះរបស់យើងយកមកផ្សំហូបទៅយើងចេះតែចែកគ្នាហូបអញ្ចឹងឯងទៅ!

គៈ មានត្រសក់មានអីនឹងចែកគ្នាបេះហូបទៅកូន!

ឃៈ ចុះអត់ដែលទិញសាច់ទិញអីទេហែសយាយ? (សំលេងរបស់មនុស្សស្រី)!

គៈ អត់សោះម៉ងមិនដែលទៅស្គាល់រស់ជាតិសាច់គោសាច់ក្របីអីនឹងទេជំនាន់! (សំលេងរបស់លោកយាយ)!

ខៈ បន្លែយើងធម្មជាតិណាស់!

កៈ ចាសលោកតា! ហើយទៅលោកតាកាលពីពេលដែលលោកតានៅក្មេងៗនឹងលោកតាចូលចិត្តលេងល្បែងអីគេដែរលោកតា?

គៈ យាយអត់ដែលបានហូបសាច់គោទេអញ្ចឹង? (សំលេងរបស់មនុស្សស្រី)!

ឃៈ អត់ទេមិនដែលទៅបានស្គាល់សាច់គោអីទេ សាច់ជ្រូកក៏ដោយ! (សំលេងរបស់លោកយាយ)!

គៈ តាំងពីក្មេងមក?

ខៈ កាលដែលតានៅពីក្មេងមកនឹងចូលចិត្តលេងកីឡា....

ឃៈ អត់ដែលហូបទេតាំងពីក្មេងនឹងមកណាស់! (សំលេងរបស់លោកយាយ)!

ខ៖ ទាត់បាល់ទាត់អីនឹង វ៉ៃសីវ៉ៃអីនឹងឯងទៅ(សើច) រួចបើដូចជាល្បែងស៊ីសងអីនឹងខ្ញុំមិនដែលទេ!

យ៖ ស្គាល់តែសម្លរម្ជូរ ប្រហើរ កកូរនឹងឯង! (សំលេងរបស់លោកយាយ)!

ក៖ ចុះលោកតាចូលចិត្តស្តាប់បទចំរៀងដែរឬទេកាលនឹងលោកតា?

ខ៖ បាទ កាលនឹងទេបើពីដើមកាលដែលខ្ញុំនៅពីក្មេងមកនឹងមកបើដូចបទចំរៀងអីនឹងចូលចិត្តស្តាប់ណាស់នាងព្រោះបទចំរៀងពីដើមគេមានអត្ថន័យល្អណាស់នាង!

ក៖ ចាសលោកតា!

ខ៖ ចំរៀងរបស់គេមានអត្ថន័យល្អណាស់មីនាងតាំងពីជំនាន់លោកតា....

គ៖ ស៊ិន ស៊ីសមុត (សំលេងរបស់លោកយាយ)!

ខ៖ បាទស៊ិន ស៊ីសមុតនឹងអី ហើយទៅនឹង សិរី សោភ័ណ្ឌ ម៉ន ដេត រស់ សិរីសុធាអីនឹង!

គ៖ ឥលូវនឹងស្លាប់អស់ហើយ!

ខ៖ បាទចំរៀងរបស់គេនឹងមានអត្ថន័យណាស់ ដូចនៅពេលដែលនៅគេការពារជាតិការពារអីនឹង ការពារវប្បធម៌អីណាស់ធ្វើអោយយើងស្តាប់ទៅនឹងធ្វើយើងនឹងមានអារម្មណ៍ស្រងេះស្រងោចណាស់ ហើយទៅជាពិសេសនឹងលោកយាយៗនឹងចូលចិត្តស្តាប់ណាស់!

គ៖ ចំរៀងយាយៗតាៗចូលចិត្តនឹងមានតែចោលឈ្នូង ដាក់បង្កៃ(សើច)!

ខ៖ បាទ (សើច)!

ក៖ (សើច) ចាសលោកយាយ!

គ៖ មិនទៅដែលស្គាល់រសជាតិអីដូចគេអញ្ចេះទេ(សំលេងរបស់លោកយាយ)!

ក៖ ចាសលោកយាយ!

ខ៖ បាទនឹងហើយ!

គ៖ លេងអង្គញ់(សំលេងរបស់លោកយាយ)!

ក៖
ចុះលោកតាកាលនឹងតើលោកតាមាននៅចងចាំបទចំរៀងអីគេខ្លះដែរតាំងពីមុនរហូតមកដល់ឥលូវនឹងណាស់លោកតា?

ខ៖
អឺម...ពីមុននឹងបទចំរៀងនឹងយើងមានការចងចាំច្រើនដែរក៏ប៉ុន្តែឥលូវនឹងយើងវាភ្លេចអស់ហើយចៅអើយ!

ក៖ ចាសលោកតា!

ខ៖ បទរាំវង់រាំអីបន្តិចបន្តួចនឹង តាចេះតែបទរាំវង់រាំអីចូលឆ្នាំចូលអីនឹងឯង(សើច)!

គ៖ ទៅដល់ទយៗ(សើច) ទ្រមួយនឹងមួយយប់ទល់ភ្លឺ! (សំលេងរបស់លោកយាយ)!

ខ៖ បាទ!

ក៖ (សើច)!

គ៖ មានតែទ្រមួយនឹង.....

ខ៖ យើងវាមិនដូចជាក្មេងសម័យឥលូវនឹងទេជំនាន់នោះណាស់ចៅ (សើច)!

គ៖ រាំស្គរដី (សំលេងរបស់លោកយាយ)!

ក៖ ចាសលោកតា!

ខ៖ អឺម! គាត់.....

ក៖ ចាសលោកតា!
អញ្ចឹងនៅក្នុងសមាជិកដែលនៅក្នុងក្រុមគ្រួសាររបស់លោកតាតើមានអ្នកណាដែលគាត់ចេះលេងឧបករណ៍ភ្លេងដែរឬទេ?

ខ៖ វាអត់ទាន់....អត់មានទេ ចេះតែអោយបង្កបង្កើតផលធ្វើស្រែធ្វើភ្លឺធ្វើការងារអីនឹង (មានសំលេងរំខានពីខាងក្រៅ) ជាមួយនឹងរដ្ឋនឹងធ្វើទាហានធ្វើប៉ូលីសអីនឹង!

ក៖ ចាសលោកតា!

ខ៖ បាទ!

កៈ
ហើយទៅលោកតាផ្ទះរបស់លោកតាមានលក្ខណយ៉ាងណាលោកតាតាំងពីក្មេងរហូតមកដល់ឥលូវនឹងណាស់លោកតា?

ខៈ នេះផ្ទះតាំងពីក្មេងរហូតមកដល់ឥលូវនឹងផ្ទះពីមុននៅនេះឆេះអស់ទៅហើយ(សើច)!

គៈ នៅស្រុកផ្សារតែអញ្ចឹងស្រុកផ្សារ! (សំលេងរបស់លោកយាយ)!

ខៈ បាទ!

គៈ គាត់ទៅនៅដល់ជំពូវន្តុងណោះ! (សំលេងរបស់លោកយាយ)!

ខៈ បាទកាលនឹងខ្ញុំទៅនៅជាមួយនឹងលោកយាយឯជំពូវន្តុងណោះ បានផ្ទះទាមនឹងមើលដល់តែពេលចាក់ដីទៅចង់លិចបង្អួចហើយថៅឯងមើលផ្ទះយើងធ្វើមុនគេនោះ បាទៗ!

គៈ គេចាក់ជុំវិញនឹង! (សំលេងរបស់លោកយាយ)!

កៈ អឹម!

ខៈ នៅមិនទាន់នឹងបានធ្វើផង!

កៈ ផ្ទះនឹងម៉ូតអីនឹងដែលលោកតា?

ខៈ អឹម...មិនដឹងម៉ូតអីទេផ្ទះនឹងផ្ទះ...

គៈ ផ្ទះតូចទាមនឹង! (សំលេងរបស់លោកយាយ)!

ខៈ ផ្ទះទាមនឹង!

កៈ ផ្ទះនឹងឆេះហ៎លោកតា?

ខៈ បាទផ្ទះទៅនឹងវាម៉ូត...

គៈ ផ្ទះថ្ម (សំលេងរបស់លោកយាយ)!

ខៈ រៀបថ្មនឹងក្រោម ហើយឥដ្ឋនឹងនៅលើបាទ!

កៈ អឹម! កាលនឹងម៉េចបានជាឆេះអញ្ចឹងលោកតា?

ខៈ បាទជួលអោយគេ អាបន្ទប់ដែលនៅខាងក្រោមនឹងជួលអោយទៅគេអ្នក...

គ៖ អែតចាយ! (សំលេងរបស់លោកយាយ)!

ខ៖ អ្នកអែតចាយ ហើយទៅម្ចាស់នឹងគេធ្វើការបាត់ហើយទៅម៉ោងប្រាំបីនឹងគេដុតហ្គាស់នឹងទៅ!

ក៖ ខ្ទុះកំប៉ុងហ្គាស់ហ៎លោកតា?

ខ៖ បាទ អ៊ឹមកាលនឹងវា...

គ៖ ឆេះទៅរត់ចេញពីផ្ទះអស់ទៅ(សើច)!

ខ៖ អត់មានមានបានយកអីទៅទេកាលនឹង ទៅបានតែម៉ូតូដែលជិះទៅនឹងដែលបានមកវិញនឹងហើយយើងមកម៉េចនឹងទាន់បើទៅធ្វើការអស់ហើយម៉ោងប្រាំបីហើយនឹង!

គ៖ អស់រលីង!

ក៖ អ៊ឹម!

ខ៖ បាទ ខ្ញុំរត់ទៅពីនេះទៅនឹងរត់អត់ទាន់ផងចូលអត់ចុះ បានថាមកពីគេដាក់អែតចាយនឹង រួចបើថាអត់ការងារក៏អត់ទៅកុំអោយតែភ្លើងឆេះផ្ទះណាស់ចៅ!

ក៖ ចាសលោកតា! លោតាហើយទៅកាលនឹងផ្ទះនឹងលោកតាជួលគេធ្វើឬក៏សាងសង់ដោយខ្លួនឯងដែរលោកតា?

ខ៖ សាងសង់ផ្ទះនឹងជួលគេ!

ក៖ អ៊ឹម!

ខ៖ បាទចៅ!

ក៖ ហើយទៅសំភារៈអីនឹងលោកតាទិញចូលមក....

ខ៖ ទិញគេបាទ សំភារៈ អីនឹងគឺយើងទិញគេមកទេហើយទៅអោយជាងគេធ្វើទៅជួលគេទៅ(មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកតា! អឺ....អញ្ចឹងលោកតានៅក្នុងសមាជិកឬក៏លោកតាផ្ទាល់នឹងចេះប្រើលក្ខណាថាដើម្បីឬក៏ចេះមានការច្នៃប្រឌិតវល្លិអីនឹងយកមកប្រើប្រាស់អីដែរឬទេលោកតា?

ខៈ អត់ទេអត់មានទេចៅ គ្រាន់តែថាមានតែទ្រព្យសម្បត្តិកន្ទេលខ្នើយពូកអីនឹងចៅ!

កៈ ចាសលោកតា!

គៈ ខោអាវ (សំលេងរបស់លោកយាយ)!

ខៈ ខោអាវ!

កៈ អញ្ចឹងសព្វថ្ងៃនឹងលោកតាកាន់ព្រះពុទ្ធសាសនាត្រូវទេលោកតា?

ខៈ បាទខ្ញុំកាន់ព្រះពុទ្ធសាសនា!

កៈ ចាសលោកតា!

គៈ កាន់ព្រះពុទ្ធសាសនា! (សំលេងរបស់លោកយាយ)!

កៈ អញ្ចឹងតើលោកតាកាន់សាសនាព្រះពុទ្ធសាសនានឹងតាំងពីពេលណាមកដែរលោកតា?

ខៈ បាទ តាំងពីយូរហើយមើលខ្ញុំកាន់តាំងពីអាយុ....

គៈ ៦០ឆ្នាំ មកម្លេះ! (សំលេងរបស់លោកយាយ)!

ខៈ តាំងពីចូលបួសដល់មកកាន់ជាមួយនឹងយាយនេះឆ្នាំ៩៣នឹង (ឆ្នាំ ១៩៩៣) នៅពេលដែលសម្ដេចទ្រង់ចូលមកវិញនឹងខ្ញុំក៏ចូលវត្តម៉ង កាន់សីលប្រាំបីមកម៉ង!

គៈ ឆ្នាំ៩៣នឹង (ឆ្នាំ ១៩៩៣)!

ខៈ នៅក្នុងឆ្នាំ៩៣នឹង (ឆ្នាំ ១៩៩៣)!

កៈ ចាសលោកតា!

ខៈ បាទ!

កៈ ចាសលោកតា! ហើយទៅលោកតាមានដូចជាការលំបាកអីគេខ្លះដែរលោកតា?

ខ៖ បាទ សុំសីលនឹងមិនទៅមានការលំបាកអីទេ យើងមកៗនឹងគឺមកធ្វើការសង្រួមចិត្តរបស់យើងបើយើងពិបាកៗតែយើងនៅពេលថ្ងៃសីលនឹង យើងវាអត់បាយនៅពេលល្ងាចណាស់!

គ៖ សុំសីលប្រាំបី (សំលេងរបសលោកយាយ)!

ខ៖ យើងដូចជាកាន់ទៅតាមវិន័យរបស់ព្រះ គឺដើម្បីតែយើងបានសុខដែរនឹងបានតែយើងខំប្រឹងធ្វើនឹង កូនចៅអីនឹងក៏គេបានសុខបានចម្រើនទាំងអស់គ្នា!

ក៖ ចាសលោកតា! អញ្ចឹងព្រះពុទ្ធសាសនាជះឥទ្ធិពលអ្វីខ្លះនៅក្នុងជីវិតរបស់លោកតា?

ខ៖ បាទជីវិតមនុស្សបើនិយាយពីរឿងរបស់ព្រះពុទ្ធសាសនាវិញនឹងគឺជះឥទ្ធិពលខ្លាំងណាស់ព្រះអង្គដល់កូនចៅទាំងអស់អោយធ្វើតែអំពើល្អ កុំធ្វើអំពើបាប កុំឈ្នានីសគេ ចេះជួយគ្នា....

គ៖ កុំច្រណែនគ្នា! (សំលេងរបស់លោកយាយ)!

ខ៖ ជួយគ្នាអត់ចេះនឹងជួយគ្នា បាទកុំអោយច្រណែនគ្នា កុំឈ្នានីសគេ បើឃើញគ្នាលំបាកហើយយើងជួយគ្នាអញ្ចឹងទៅ ជួយទុកធុរៈគ្នាអញ្ចឹងឯងទៅកន្លែងណាៗអី!

គ៖ ចេះជួយគ្នាទៅវិញទៅមក ដូចយាយៗនៅនឹងវត្តនឹង! (សំលេងរំខានពីខាងក្រៅ)!

ខ៖ បាទនឹងហើយដូចជាយាយៗដែលនៅវត្តនឹង!

គ៖ មើលលំនាំរបស់គាត់នឹងទៅ កុំអោយមានទំនាស់គ្នា ចេះដឹកនាំពួកគាត់ទៅកុំអោយច្រណែនគ្នាមើលងាយគ្នា!

ខ៖ បាទកុំអោយគ្នាហាមាត់មករកហើយយើងទៅ....បើថាគាត់មានចិត្តច្រណែននឹងក៏កុំទៅតមាត់តកអីនឹងគាត់អីអ្នកណាគេធ្វើអ៏ក៏ធ្វើទៅគាត់ធ្វើហើយមិនបានយើងទៅជួយរំលែកគាត់ទៅបាទ អញ្ចឹងឯងចៅ!

ក៖ ចាសលោកតា!

ខ៖ បាទនៅក្នុងព្រះសាសនាទ្រង់មានតែពាក្យប្រដៅដល់យើងគ្រប់គ្នានឹងតែប៉ុណ្ណឹងឯងទេ!

កៈ ចាសលោកតា!

ខៈ អោយទាំងអស់គ្នានឹងប្រណិប័តតាមតែប៉ុណ្ណឹង!

កៈ ចាសលោកតា!

ខៈ បាទ!

កៈ
ចុះចំពោះការក្រុមគ្រួសាររបស់លោកតាជឿរទៅលើព្រះសាសនាទាំងអស់គ្នាឬក៏ម៉េចដែរលោកតា?

គៈ ជឿរទាំងអស់ (សំលេងរបស់លោកយាយ)!

ខៈ បាទជឿរទាំងអស់គ្នា!

កៈ អឹម! តើប្រពៃណីសាសនាណាដែលក្រុមគ្រួសាររបស់លោកតាអនុវត្តន៍?

ខៈ បាទអត់ទេ បាទខ្ញុំកាន់តែសាសនារបស់ព្រះពុទ្ធនឹងទេថៅ បាទ!

កៈ ចាសលោកតា! អញ្ចឹងតើមានកម្មវិធីអីគេខ្លះទាក់ទងជាមួយនឹងសាសនារបស់ព្រះពុទ្ធសាសនាដែលក្រុមគ្រួសាររបស់លោកតាតែងតែអនុវត្តន៍ផ្ទាល់ម៉ងណាស់លោកតា?

គៈ អត់មានទេ (សំលេងរបស់លោកយាយ)!

ខៈ បាទៗអត់មានទេថៅ! បើមាននឹងមានតែយើងដូចថានៅខែមន់សន់រដូវភ្ជុំបិណ្ឌអីនឹង!

គៈ ខែភ្ជុំបិណ្ឌអីនឹង! (សំលេងរបស់លោកយាយ)!

កៈ នឹងហើយលោកតា!

ខៈ បាទ បុណ្យកបិនអីនឹងយើងចូលឆ្នាំអីនឹងណាស់ យើងមកជួបជុំគ្នាដើម្បីនឹងមកគោរពវិញ្ញាណខន្ធជូនទៅដល់ជីដូនជីតាជីតាតែប៉ុណោះបាទ!

គៈ ជូនទៅដល់ជីដូនជីតា! (សំលេងរបសលោកយាយ)!

ខ៖ បាទ ដើម្បីយើងនឹងបានសេចក្តីសុខដូចថាយើងរំលឹកនឹកគុណរបស់គាត់ណាស់ទានណាស់បាទៗ!

គ៖ កូនចៅមកលេងហើយចេះតែទៅទទូលគាតទៅ! (សំលេងរបស់លោកយាយ)!

ខ៖ បាទធ្វើតអញ្ចឹងមកតាំងពី...

គ៖ អោយពរអោយជ័យទៅ វិញ្ញាណខន្ធវិញ្ញាណអីអញ្ចឹងទៅ!

ខ៖ ព្រះបរមគ្រូគាត់បានផ្តាំមកថាអោយយើងម៉េច អោយចេះជួយគ្នា អោយចេះនឹកគុណទៅដល់មាតាបិតារបស់យើងដូចថាមាតានៅផ្ទះជាព្រះដើម!

ក៖ ចាសលោកតា!

ខ៖ បាទហើយព្រះដែលនៅនឹងវត្តគឺគ្រាន់តែជាតំណាងអោយរូបរបស់ព្រះពុទ្ធនឹងអោយយើងពិចារណាទៅទេមានតែព្រះដើមរបស់យើងនឹងគាត់ហាត់នឿយណាស់!

ក៖ ចាសលោកតា!

ខ៖ អញ្ចឹងបានថាមានតារបស់យើងគាត់ល្អណាស់...

គ៖ ពិបាកណាស់ទាំងថ្ងៃទាំងយប់ ដើរឈរអង្គុយទាំងអស់នឹងចឹងហើយយើងត្រូវចេះដឹងគុណរបស់គាត់ ហើយមកនេះយើងត្រូវចេះដឹងគុណរបស់ព្រះពុទ្ធសាសនា!

ខ៖ បង្រៀនយើងតាំងតែពីយើងចាប់បដិសន្ធិបានមួយថ្ងៃនឹងរហូតមកបានប្រាំបួនខែដប់ថ្ងៃគាត់ថ្នមយើងមករហូត ហើយកូនកើតភ្លេចមកនឹងអូ...ថ្នមយើងមករហូតមកហ៊ានអោយយើងមានស្រមោចវាលើទេបាទ បើរកអីប្រៀបមិនស្មើទេបាទ រឿងគុណរបស់តាមាបិតានឹងណាស់!

គ៖ គុណនោបការៈរបស់គាត់គឺព្រះពុទ្ធព្រះធម៌ព្រះសង្ឃ!

ក៖ ចាសលោកតា!

ខ៖ បាទ!

ក៖ ចុះលោកតាអាចប្រាប់ខ្ញុំបានទេថា លោកតាមានធ្លាប់បានជួបទៅនឹងបញ្ហាអីគេខ្លះនៅក្នុងជីវិតតាំងពីមុននឹងរហូតមកដល់ឥលូវនឹងណាស់?

ខ៖ បាទបញ្ហាដែលជួបមាននៅក្នុងជីវិតនឹងគឺកាលពីយើងនៅធ្វើជាទាហាននោះវា...

គ៖ ដូចថាវាកន្លងហួសអស់ទៅហើយនិយាយមិនចេញ! (សំលេងរបស់លោកយាយ)!

ខ៖ បាទដូចថារឿងវាកន្លងផុតអស់ទៅហើយនិយាយមិនចេញទេនិយាយលែងចេញហើយថៅ (សើច) បាទការពិបាកនឹង!

គ៖ គេទៅវិញហើយ (សំលេងរបស់លោកយាយ)!

ខ៖ ជួនណាទៅៗធ្វើជាទាហាននឹងខ្មែរក្រហមវា...

គ៖ យើងមិនចង់សើរើវាមករំលឹកវាមកវិញហើយ! (សំលេងរបស់លោកយាយ)!

ខ៖ ប៉ុលពតវាព័ន្ធយើងជាប់ជួនណាជាប់កន្លះខែអីណោះបានចេញរួចជួនណាទៅគេទំលាក់បាយអីនឹងអោយយើងស៊ីនឹងមកមើលអាប៉ុលពតនឹងវាយកទៅបាត់ឯងឡើយតែនៅក្នុសភា
អត់បានហូបអីដេកអត់បាយនឹងក៏មានដែរអារឿងបញ្ហានឹងជារឿងធម្មតាទេ
កាលនឹងកាលយើងមានសង្គ្រាមបាទ!

គ៖ ហ៊ើយ! ជំនាន់នោះពិបាកណាស់កូនអើយ អាយុប៉ុណ្ណឹងៗទៅហើយស្គាល់អស់ទៅហើយគ្រប់បញ្ហានៅក្នុងជីវិតនឹង
ហើយបើមកដល់ពេលចប់អស់ហើយ!

ខ៖ អញ្ចឹងបានម្នាក់ៗខ្លាចរអាណាស់ឥលូវនឹងណាស់ចាស់ៗនឹងគាត់ខ្លាចណាស់ បើថាហ៊ានតាំកើតចម្បាំងនឹងឡើងមកអត់ងាប់អ្នកណាទេងាប់តែកូនអ្នកក្រនឹង
បាទមានតែយើងទាំងអស់គ្នានឹងហើយងាប់កូនអ្នកក្រនឹងចេញទៅធ្វើជាទាហាននឹងអស់

គ៖ អត់ហ៊ាននិយាយស្គាល់តែព្រះពុទ្ធព្រះធម៌ព្រះសង្ឃនឹងទេ ស្គាល់តែប៉ុណ្ណឹងទេនាងស្គាល់តែគុណរបស់មាតាបិតាតែប៉ុណ្ណឹងឯងទេនាងស្គាល់តែប៉ុណ្ណឹងឯងមកយើងចំណាស់នឹងហើយ!

ខ៖ បាទ!

កៈ អឺម! និយាយថាបទពិសោធន៍ជីវិតរបស់លោកតានឹងច្រើនអញ្ចឹងណាស់!

ខៈ បាទ!

កៈ
តាំងពីមុនរហូតមកដល់ឥលូវនឹងឆ្លងកាត់អីគេខ្លះដែរលោកតាដែលពិបាកណាស់លោកតា?

ខៈ អឺម! ឆ្លងកាត់ដូចជាជំនាន់ប៉ុលពតនឹងហើយដែលពិបាកជាងគេបាទ!

គៈ ជំនាន់នឹងជំនាន់ដែលពិបាកជាងគេធ្វើការគ្មានបានសំរាកផង...

ខៈ បាទជំនាន់បីឆ្នាំ ប្រាំបីខែ មួយម្ភៃថ្ងៃនឹងហើយបាទ...

គៈ អាសន្នរោគនឹងផង បារាំងផង ប៉ុលពតនឹងផងប្អូនមុខណាស់ន៏តា? (សំលេងរបស់លោកយាយ)!

ខៈ យាយវាឯងអានឹងវាមួយជំនាន់ៗនឹង...

គៈ អើ! មួយជំនាន់នឹង ជំនាន់បារាំងនឹងនោះផ្សេងទៅ! (សំលេងរបស់លោកយាយ)!

ខៈ កាលដែលជំនាន់បារាំងនោះយើងសម្តេចឪទ្រង់បានទាមទារឯករាជ្យមកហើយ!

គៈ រួចជំនាន់ឥស្សរៈនោះផ្សេងទៅ! (សំលេងរបស់លោកយាយ)!

ខៈ បាទ អានឹងយើងឥស្សរៈនឹងជំនាន់បារាំង!

គៈ ជំនាន់អាសន្នរោគនឹងផ្សេងងាប់ច្រើនណាស់មួយថ្ងៃៗនឹងសឹងតែថាក្រាលដី!

ខៈ បាទ យើងឆ្លងកាត់...

គៈ ប៉ុន្តែចេះតែមានមនុស្សរស់នៅមកដល់សព្វថ្ងៃនឹងណាស់!

ខៈ ប្អូនរបបបីរបបមកហើយ!

គៈ ជំនាន់អាសន្នរោគណាស់មនុស្សងាប់ក្រាលដីហើយ អាចារ្យនឹងរកមិនចង់ទាន់តែជញ្ជូនដូចអីអញ្ចឹងជំនាន់អាសន្នរោគណាស់តា បានថាមិនបាច់សួរជំនាន់ទេតែអាយុ៧០ឆ្នាំ ៨០ឆ្នាំ នឹងហើយចប់ហើយលោកអើយលោកពិបាកនិយាយណាស់ពិបាកណាស់បញ្ហានៅក្នុងជីវិតនឹង! (សំលេងរបស់លោកយាយ)!

ឃៈ បាទ (សំលេងមនុស្សប្រុស)!

ខ៖ បាទអញ្ចឹងបានថា រឿងជីវិត...

ក៖ ចាសលោកតា ដោយសារតែមនុស្សរបស់យើងម្នាក់ៗនឹងគាត់មានការលំបាកនឹងផ្សេងៗពីគ្នាអញ្ចឹងណាស់លោកយាយ?

គ៖ ចាស ការលំបាកនឹងផ្សេងៗពីគ្នា!

ខ៖ បាទការលំបាកនឹងវាផ្សេងៗពីគ្នាជូនណាទៅកន្លែងស្រុកភូមិដែរនៅតាមខេត្តអញ្ចឹងទៅគាត់ផ្សេងទៅ ដូចជំនាន់នឹងក៏អញ្ចឹងដែរហ៎គេអោយយើងទៅភូមិភាគនេះភូមិភាគនោះអញ្ចឹងទៅគេបានស៊ីដូចថាគេបានស៊ីឆ្អែតអញ្ចឹងទៅ...

គ៖ គេបានស៊ីបាយទៅ ហើយទៅឯងនឹងស៊ីបបរអញ្ចឹងទៅ! (សំលេងរបស់លោកយាយ)!

ខ៖ ហើយឯងឯណោះដេកអត់អញ្ចឹងទៅបាទ អញ្ចឹងបានថាពិបាកណាស់នាង!

គ៖ ហើយខ្ញុំឯណោះនឹងគល់ចេកអញ្ចឹងឯងទៅ ហើយពិបាកណាស់លោកអើយលោក(សំលេងរបស់លោកយាយ)!

ក៖ អញ្ចឹងកាលពីជំនាន់នឹងលោកតាមានបងប្អូនស្លាប់នៅក្នុងជំនាន់ប៉ុលពតដែរឬទេលោកតា?

ខ៖ នៅក្នុងជំនាន់ប៉ុលពតនឹងស្លាប់ប្អូននាក់ប្រុសៗ!

ក៖ អឹម! (មានសំលេងរំខានពីខាងក្រៅ) លោកតាទាន់ពួកគាត់ដែរឬទេលោកតា?

ខ៖ អត់ទាន់ផងនាងបែកគ្នាកាលនឹងមិនដឹងអ្នកណាទៅនៅខាងណាខ្លះទេនាងគេបំបែកខ្ញុំអោយទៅនៅភូមិស្រុកនឹងជិត...

គ៖ គេជំលៀសទៅនឹង គេអត់អោយយើងរកគ្នាទេ អត់អោយរកគ្នាទេ!

ខ៖ ខ្ញុំគេអោយទៅជិតព្រំដែនយួនឯណោះ ជិតខេត្តណាំងត្រាញ បាទបែកគ្នាអស់ហើយ!

គ៖ ចេញក្រៅអត់បានទេ (សំលេងរបស់លោកយាយ)!

ក៖ អញ្ចឹងកាលនឹងគេអោយលោកតាធ្វើអីគេខ្លះដែរលោកតា?

ខ៖ ទៅដល់នឹងគេអោយយើងធ្វើស្រែដល់តែអោយយើងធ្វើស្រែនឹងហើយ (មានសំលេងរំខានពីខាងក្រៅ) ចេះឡើងត្នោតឡើងអីនឹងទៅខ្ញុំ!

គ៖ ធ្លាប់ឡើងពីដើម (សំលេងរបស់លោកយាយ)!

ខ៖ បាទធ្លាប់ឡើងពីដើមជាមួយនឹងឪពុកប៉ុន្តែមិនដែលបានឡើងទៅធ្វើទេណាស់ គ្រាន់តែទៅជួយដាក់បង្អោងគាត់នឹងទេណាស់ អត់ទេឯងគ្រាន់តែថាចេះឡើងត្នោតគេអោយឡើងត្នោតបបរជីដាក់ទៅពីរទេះគោទៅព្រលឹម ឡើងនឹងគេអោយយើងឡើងដើមត្នោត (សំលេងសើច) ឯងឯណោះភ័យញ័រជើងឡើងមិនចង់លជាប់ទេ!

គ៖ (សើច) ចេះបររទេះទៀត! (សំលេងរបស់លោកយាយ)!

ខ៖ យើងពេលឡើងទៅនឹងមិនដាក់អាបំពង់នឹងទៅដែរ នោះមិនមែនមិនចេះគៀបអោយចេញទឹកទៅឯណា!

ខ៖ ដើមត្នោតនឹងខ្ពស់ៗណាស់! (សំលេងរំខានពីខាងក្រៅ)!

គ៖ បាទហើយទៅខំទៅទាក់ទងជាមួយនឹងគេនៅក្នុងភូមិនឹងហើយទៅមានតែម្នាក់ទៀតចេះឡើងត្នោតគាត់ចេះឡើងត្នោត នឹងហើយទៅខ្ញុំចេះសួរគាត់ថាលោកតាឡើងនៅស្រុកនឹងគេឡើងត្នោតម៉េចទៅទើបបានទឹកហើយ....

គ៖ ហើយឡើងដើមត្នោតរបូតដៃរបូតជើងមកធ្លាក់ងាប់! (សំលេងរបស់លោកយាយ)!

ខ៖ នៅស្រុកខ្ញុំគ្រាន់តែធ្វើច្របាច់ចេញទឹកនឹង ហើយទៅគាត់ចង្អុលថាគាត់អញ្ចេកនែ អាចៅឯងកុំណាស់នៅស្រុកនេះគេរ៉ៃចោលអស់ប៉ុន្មាននាក់ហើយអ្នកអួតៗនឹង ហើយឯងនេះកាន់តែភ័យ(សើច)!

ក៖ (សើច)!

គ៖ និយាយមិនអោយគ្នាភ័យម៉េចលោកហើយ! (សំលេងរំខានពីខាងក្រៅ)!

ខ៖ ហើយទៅគាត់ថាអោយមើលហើយចងភ្លែតៗទៅ ហើយទៅបានគាត់ថាអាចៅឯងបានចេញមកអញ្ជឹងស្រួលណាស់អត់អីទេ

អឹមហើយទៅបានគាត់ប្រាប់នៃអាថៅឯងបានចេះមកសួរតាអញ្ចឹងនឹងស្រួលហើយណាស់អឹម ! ដល់ហើយបានគាត់ប្រាប់ថាអាថៅឯងធ្វើម៉េចគៀបអោយខ្លាំងគល់នឹង អឹម! ដល់ហើយបានធ្វើតាមគាត់នឹងទៅលោកអើយទឹកចេញមែន ចេញមកពេញៗបំពង់!

គ៖ គៀបវាអោយដល់គល់ចុះមក(សំលេងរបស់លោកយាយ)!

ខ៖ គៀបខាងគលនឹងអោយខ្លាំងហើយខាងចុងនឹងគៀបតែបន្តិចៗនឹងទៅបាន!

គ៖ អញ្ចឹង?

ខ៖ បាទ!

គ៖ ជ្រុំៗវានឹងទៅ ហើយទៅទឹកហូរចូលទៅ! (សំលេងរបស់លោកយាយ)!

ខ៖ បាទ ហើយទៅត្នោតនៅស្រុកនោះមែនយើង យ៉តនឹងអត់មានទឹកហូរទេ ខ្ញុំឡើងទៅហើយដល់ពេលដែលខ្ញុំឡើងទៅនឹងឃើញគេដែលឡើងទៅមុននឹងគេចិតដល់ខ្ចីប ត្នោតនឹងចេញជ័រ ដល់ហើយបានថាអូ...ដល់មែនដូចគាត់ប្រាប់មែន ហើយទៅខ្ញុំនឹងពួយម៉ងគៀបគល់នឹងអោយច្រើនបាទ!

គ៖ គាត់ធ្វើធ្លាប់ឡើង! (សំលេងរបស់លោកយាយ)!

ខ៖ គាត់ធ្លាប់ឡើងដើមត្នោតមុនបាទ!

ក៖ ចាសលោកតា! ហើយចុះកាលនឹងគេយកទឹកត្នោតនឹងទៅធ្វើអីដែរលោកតា?

ខ៖ យកទៅរំម្ចាស់ធ្វើជាស្ករ!

ក៖ គេមានធ្វើស្ករដែរន៍?

ខ៖ រម្ចាស់ស្ករយកទៅធ្វើថ្នាំ ថ្នាំឧសថនោះណាស់!

ក៖ ចាសលោកតា!

ខ៖ របៀបថ្នាំឧសថនឹង! (មានសំលេងរំខានពីខាងក្រៅ)!

ក៖

លោកតាហើយទៅកាលពីជំនាន់នឹងលោកតាមានដែរឃើញគេយកមនុស្សទៅស្លាប់ចោលដែរ ឬទេ?

ខ៖
អូ...ខ្ញុំគេនាំទៅដែរពេលទៅមុនដំបូងនឹងឆ្នាំនេះ...ទៅភូមិនឹងទាហានទៅខាងត្បូងភ្នំស្រង់នេះ!

ក៖ អឺម!

ខ៖ ស្រាប់តែនាងអើយគេហៅខ្ញុំអើចុះពេលនឹងគេហៅខ្ញុំ ទៅដល់គេខ្ញុំនឹងដើរអ្នកថ្មីនោះទៅគេសង់ខ្ទមៗរោងចឹងៗអោយសុទ្ធតែចិន
ហើយទៅខ្ញុំដើរជាមួយគេអ្នកណានិយាយអីនិយាយទៅយើងសុំតែមួយរួចខ្លួននិយាយគ្នានឹងសុទ្ធតែអ្នកដែលយើងទុកចិត្តគ្នាហើយបានដើរជិតអ្នកកាន់សីលអ្នកធម៌អ្នកអារ្យដែរ!

គ៖ យើងបានជួបជាមួយនឹងអ្នកដែលគេមានចិត្តល្អ! (សំលេងរបស់លោកយាយ)!

ខ៖ បាទហើយទៅចេះតែដេកស្តាប់អីជាមួយនឹងគេនឹងឯងទៅហើយទៅថ្ងៃមួយនឹងឃើញដឹកចងទាហានមក ទាំងរ៉ូងៗយកគ្នាទៅសំលាប់ចោលម៉ងហើយហើយនៅថ្ងៃមួយនោះគេជីករណ្តៅហើយអីហើយនឹងអាទាហានលឺគេថាអើគេឃើញចេញពីទំនប់ពីប្រឡាយមក
ឯងសួរទៅណាគេថាទៅស្រុកអស់ហើយគេបញ្ជូនទៅស្រុកអស់ហើយអានោះឈឺបន្តិចបន្តួចខំធ្វើជាឈឺដែរ!

ក៖ អឹម!

ខ៖ គេយកមកហើយថ្ងៃនឹងគេជីករណ្តៅជីកអីរួចហើយអស់ហើយអូ...ខ្ញុំញាក់ស្រឹតនៅថ្ងៃនឹងឃើញមាត់រណ្តៅគេអោយយើងទៅអង្គុយនៅនឹងមាត់រណ្តៅនឹងឯងណាស់យាយ!

គ៖ អឺស!

ខ៖ បាទថា (សំលេងរំខានពីខាងក្រៅ) ជិតតែនឹងទៅហើយ!

គ៖ គេដឹកយកទៅហើយទៅចងគ្នាទាំងខ្សែៗនឹង! (សំលេងរបស់លោកយាយ)!

ខ៖ បាទអញ្ចឹងបានថា!

គ៖ បាត់យើងតែមួយម៉ោងក៏ទាហានដែរ គេយកទៅវ៉ៃចោលហើយ (សំលេងរបស់លោកយាយ)!

ក៖ ចាសលោកយាយ! ចុះលោកតាកាលពីជំនាន់នឹងលោកតាចងចាំនៅទិដ្ឋភាពអីគេខ្លះដែរលោកតាកាលពីជំនាន់នឹង?

ខ៖ ចងចាំទិដ្ឋភាពនឹងអឺម...គេថានៅក្នុងរបបនឹងឯងគេថាអោយខ្មែរយើងនឹងអោយចេះស្រលាញ់គ្នាអ៎...អោយស្មើរៗគ្នាអត់អោយមានអ្នកណាមានអ្នកក្រអីនោះទេ!

គ៖ ក្រក៏ក្រទៅកុំអោយតែមាន អោយតែក្រ!

ខ៖ ចញ្ចឹងណាស់អោយស្មើរគ្នាទាំងអស់គ្នានឹង!

គ៖ ស្មើត្រឹមម៉ង! (សំលេងរបស់លោកយាយ)!

ខ៖ បាទបានថាមហាសែនយ៉ាប់នោះ!

គ៖ រួចបើស្លៀកពាក់វិញនឹងកុំមុយនីស!

ខ៖ សូម្បីតែយើងស្លៀកពាក់នឹងក៏មានបាននេះ ស្លៀកពាក់នឹងបានតែខ្មៅទេណាស់!

គ៖ អោយសុទ្ធតែខ្មៅ!

ខ៖ ស្លៀកពាក់ខ្មៅហើយចងក្រមារនឹងក នេះ!

គ៖ ចងក្រមារ!

ខ៖ ហើយស្បែកជើងក៏ខ្មៅដែរអាស្បែកជើងកង់ឡាន!

គ៖ អូ...ជំនាន់នឹងពាក់ស្បែកជើងកង់ឡាន!

ខ៖ កាលនឹងគ្រាន់តែឃើញដើរមកឃើញគេនឹងយើងខ្លាចណាស់ព្រោះយើងទៅនឹងគ្មានខោអាវហើយទៅហើយជំលៀសពីភ្នំពេញទៅនឹងគេហៅអ្នក១៨មេសាហើយនឹងណាស់!

គ៖ ចាសនឹងហើយអ្នក១៨មេសារ!

ខ៖ ហើយទៅអ្នកខាងណោះគេ១៧ ហើយយាយពីរនាក់នេះ១៨!

ក៖ ចាសលោកតា!

ខ៖ អោយតែឃើញគេខោមិនខោអាវមិនអាវនឹងខ្លាចគេដើរនៅលើភ្លឺស្រែឃើញចុះភ្លែតធ្លាក់ភ្លឺស្រែហើយ(សើច)!

គ៖ (សើច) ចាស!

ក៖ ចាសលោកតា!

ខ៖ និយាយពីថាខ្លាចគេនោះកាលនៅកាលនោះអត់បានទេនៅរបបនឹង!

ក៖ ចាសលោកតា!

គ៖ និយាយពីស្បែកជើងកង់ឡាននឹងអោយយើងពាក់ណាស់(សំលេងរបស់លោកយាយ)!

ខ៖ ខ្ញុំហើយ ខ្ញុំឃើញគេចងទាហាននៅនឹងស្រុករបស់ខ្ញុំនឹងគេចងអំបោះតែមួយសសៃរតើគ្នារាប់រយនាក់...

គ៖ អឺស!

ខ៖ ហើយអាមួយនឹងគ្នាដូចថាសត្វស្អីខាំបក់ដៃអញ្ចឹងទៅដាច់អាអំបោះនឹងដល់តែដាច់អំបោះគេបាញ់ក្តូងៗដល់ហើយអ្នកដែលនៅក្បែរគ្នាចេះក្រាបទាន់ទេណាស់តែមិនអោយដាច់អំបោះទេស្រួលម៉េចម៉ាអោយវាដាច់ គ្នាដូចថាសត្វស្អីវាខាំអញ្ចឹងណាស់!

គ៖ នឹងវាថាយើងប្រលះហើយនឹងណាស់! (សំលេងរបស់លោកយាយ)!

ខ៖ នឹងហើយវាថាយើងប្រលះខ្សែបណ្តាច់នឹងបាទ!

គ៖ យើងដើកដៃអញ្ចេក វាមិនដែលគ្នាគ្រាន់តែលើកដៃអែសរមាស់មិនបានសោះយកអំបោះទៅរឹតគ្នា!

ខ៖ ហើយទៅជំនាន់នឹងក្មេងៗស្ពាយកាំភ្លើងមិនទាំងផុតពីដីផងនឹងយកទៅធ្វើ...

គ៖ អូសនឹងណាស់ អាអ្នកដែលយកយើងទៅនឹងអូនកាំភ្លើងទៅតើ តូចៗទេ!

ខ៖ បាទអូសកាំភ្លើងមិនទាន់នឹងផុតពីដីផងនឹងយកមិនទៅធ្វើខុសអី...

គ៖ ដើរមើល ៥០ ទៅ ៦០ គ្រួសារ!

ខ៖ អើ!! គេដាក់មកនឹងគេថាម៉ែឪអត់មានគុណមានគុណអង្គការគេឯណាណោះ!

គ៖ នឹងហើយសម្លាប់ចោលទាំងឪពុកម្តាយទៀត (មានសំលេងរំខានពីខាងក្រៅ)!

ខ៖ ស្លាប់រង្គៀល កាលនឹងអូយ...ជំនាន់នឹងពិបាកណាស់ចៅ!

ក៖ អឺម...កាលនឹងគេចងខ្សែអំបោះនឹងគេយកទៅស្រែនឹងហ៎លោកតាន៍ដែលគេជំលៀសយើងមុនដំបូងនឹងហ៎?

ខ៖ ចងទៅគេយកទៅកន្លែងរណ្តៅនឹងណាស់ចៅ ទាហាននឹងណាស់!

គ៖ ទាហាននឹងគេយកទៅកន្លែងរណ្តៅ!

ខ៖ ចេញទៅវាយកទៅចងតែនឹងអំបោះតែមួយសសៃរទេ គេខ្លាចយើងរត់ដឹងទេ ហើយអំបោះហុងរបស់យើងនឹងមិនចងជាប់គ្នាអញ្ចឹងមកហើយមួយទៅដាក់ប្រាំម៉ែត្រ បីម៉ែត្រដាក់មួយទៅៗនឹងឯងទៅ!

គ៖ គេចងបន្តគ្នាអញ្ចឹងទៅពេលដែលគេយកទៅជីករណ្តៅណាស់គេយកទៅរណ្តៅ! (សំលេងរបស់លោកយាយ)!

ខ៖ បាទ!

ក៖ អញ្ចឹងបើអ្នកណាគេដាច់មុនសម្លាប់មុនអញ្ចឹងឯងទៅ?

គ៖ សម្លាប់មុន!

ខ៖ អូ....បើថាដើរនៅតាមផ្លូវតែដាច់នឹងតែទៅហើយ(ស្លាប់)!

គ៖ តែដាច់ខ្សែអំបោះនឹងស្លាប់មុនហើយ (សំលេងរបស់លោកយាយ)!

ក៖ អឺម!

ខ៖ ហើយទៅទាំងយើងទាំងគេដាក់តែមួយអញ្ចឹងឃើញ...

គ៖ ចងគ្នាបណ្តើរយកទៅអញ្ចឹងនឹងដល់ហើយយកទៅដល់កន្លែងនឹងគេដាក់តែមួយគល់ឈើនឹងទៅម៉ង! (សំលេងរបស់លោកយាយ)!

ខ៖
ឃើញងាប់អញ្ចឹងនឹងគ្នាអ្នកក្រោយអត់ហ៊ានកំរើកទេចង់ហៃងម៉េចក៏ដោយអត់ហ៊ានកំរើក
សោះ!

ក៖ ហើយទៅកាលនឹងគ្នាច្រើនដែរម៉េចក៏មិននាំគ្នាតវ៉ាទៅលោកតាកាលនឹង?

គ៖ នែ!!

ខ៖ ស្រាប់ជាន់ម៉ងណាស់ចៅ!

ក៖ ដូចមានអីនេះម៉ង!

ខ៖ និយាយដូចខ្ញុំអីនឹង...

ក៖ ដូចបាក់ម៉ងហ៏លោកយាយកាលនឹងហ៏?

ខ៖ ដូច....ដូចខ្ញុំអីនឹងកាលនឹងធ្លាប់ហាត់តែខ្វាន់ដូរនៅក្នុងពេលធ្វើទាហានពីដើមនឹង
ប្រាំមួយខែហើយអាទាហាននោះទាត់តែមួយជើងងាប់!

ក៖ នឹងហើយលោកតា!

ខ៖ តែវាអត់ហ៊ានគេមកស្រាប់ជាន់ម៉ង
ទាហានកាលនឹងនៅនឹងជំនាន់របស់ខ្ញុំនឹងហាត់សុទ្ធតែតែខ្វាន់ដូនោះហើយទៅអោយគេចង!

គ៖ ទាហានសុទ្ធតែសាក់ប្រាំសាក់អីឯណោះ!

ខ៖ បាទ!

គ៖ ហើយទៅអោយកូនក្មេងតូចមួយសម្លាប់!

ខ៖ បាទ! ចេះមួយសព្វតែ ដូចយើងចាញ់ស្រាប់គេម៉ងអត់ហ៊ានមិនដឹងថារត់ទៅណាទេ!

គ៖ ចាស ចាញ់ប្រាប់គេម៉ង ចាញ់គេនឹងម៉ង!

ខ៖ បាទ! អញ្ចឹងបានថា...

គ៖ ខ្សោយម៉ង!

ខ៖ បាទ!

កៈ ចាសលោកតា! ចុះលោកតានៅក្នុងជីវិតរបស់លោកតាមានរឿងល្អៗដែរឬទេលោកតា?

ខៈ បាទ! អឺម...កាលនៅជំនាន់វាមិនសូវជាមានប៉ុន្មានទេចៅអើយ!

គៈ វាមិនសូវមានល្អអីទេ កាលជំនាន់អាពតនោះ!

ខៈ តែតាមានច្រើនដែរនឹងបាទ!

កៈ មានអីគេខ្លះដែរទៅលោកតា?

ខៈ អឺម! ដូចថាជំនាន់សម្តេចឪទ្រង់យាងមកវិញនឹងក៏សប្បាយរីករាយអញ្ចឹងឯងទៅហើយទៅមកដល់ជំនាន់ប៉ុលពតនឹងឯងក៏អត់អញ្ចឹងទៅហើយក៏ជំនាន់យើងនេះក៏បានសប្បាយទៅហើយឥលូវនឹងក៏បានរីកចំរើនហើយ ខ្ញុំថារីចចំរើនហើយឥលូវនឹងរាល់ថ្ងៃនឹងណាស់សម្តេចហ៊ុនសែន សម្តេចជាស៊ីមគាត់បានមកត្រួសត្រាយផ្លូវសាងសាលាអោយកូនចៅបានរៀនសូត្រ!

គៈ បានចេះដឹង!

ខៈ បើកាលជំនាន់ប៉ុលពតបញ្ញាវ័ន្តយកគ្នាទៅសម្លាប់ចោលអស់ហើយមួយយប់ឃើញតែយកមនុស្សទៅវ៉ៃចោល បាទ អ្នកចេះអ្នកដឹងបាទ
បានថាសោកស្តាយណាស់បាទគ្នាខំមកដល់ស្រុកគេហើយនឹងគេជំលៀសបញ្ឆោតមកយកគ្នាមកវ៉ៃចោលនៅនឹង!

គៈ អឺម! រកតែពុទ្ធោទេទេវព្តាអើយ (សំលេងរបស់លោកយាយ)!

ខៈ គុកទួលស្លែងបាទ
ទៅវាបញ្ឆោតថាអត់មានអ្នកធ្វើការទេហើយទៅយកគ្នាមកមើលយកគ្នាមកវ៉ៃចោលនៅនឹងគុកទួលស្លែងនឹង (មានសំលេងរំខានពីខាងក្រៅ)!

គៈ ហើយទៅស្លូអី? (សំលេងរបស់លោកយាយ)!

ឃៈ ស្មោរគ្រាវ! (សំលេងរបស់មនុស្សស្រី)!

កៈ អឺម....ចាសលោកតា!

ខៈ បាទ!!

កៈ
អញ្ចឹងដូចជារឿងល្អៗដែលកើតមានឡើងនៅក្នុងជីវិតរបស់លោកតាដូចជាលោកតាមានកូនចៅអីនឹងហើយ
នឹងដូចជាលោកតានៅតាំងពីក្មេងរហូតមកដល់ឥលូវនឹងលោកតាមានដែលធ្លាប់ឆ្លងកាត់រឿងល្អៗដែលធ្វើអោយលោកតាសប្បាយចិត្តណាស់លោកតា.....

ខៈ បាទ!
រឿងដែលល្អនឹងគឺថាខ្ញុំបានរៀបចំទុកដាក់កូនចៅនឹងអោយមានគូស្រករមានអីអញ្ចឹងទៅបានថាខ្ញុំរីករាយសប្បាយចិត្តដល់តែបានមកចូលប្រណិបត្តិនៅក្នុងព្រះពុទ្ធសាសនានឹងក៏រឹតតែសប្បាយចិត្តដូចថាយើងបណ្តាលចិត្តនឹកពិចារណាទៅណាស់នឹកផ្លូវល្អម៉េច
ផ្លូវអាក្រក់ម៉េចយើងធ្វើម៉េចអោយតែបានសុខនឹងទៅ បាទ!

គៈ ដាច់អាពតនឹងមកយើងត្រេចអរណាស់ទៅហើយ (សំលេងរបស់លោកយាយ)!

ខៈ បាទ!!

កៈ អឺម....ចាសលោកតា!
នឹងហើយអញ្ចឹងជាចុងក្រោយលោកតាមានជាពាក្យពេចន៏អីដើម្បីនឹងផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយណាស់លោកតា?

ខៈ បាទ ខ្ញុំសូមផ្តាំផ្ញើរទៅដល់កូនចៅជំនាន់ក្រោយណាស់ទានណាស់
សូមអោយកូនចៅនឹងគោរពទាំងអាណាចក្រ
ពុទ្ធិចក្រទាំងអស់ដែលលោកបានត្រួយត្រាយផ្លូវអោយយើងដើរមកនេះ
រកតែផ្លូវល្អទេណាស់ទានណាស់ទាំងពុទ្ធិចក្រនឹងអាណាចក្រអីទាំងអស់នឹងអញ្ចឹងហើយសូមកូនចៅទាំងអស់នឹងសូមគោរពហើយនឹងជូនពរអោយកូនចៅនឹងមានសុខភាពល្អកុំអោយមានជំងឺអីមានបៀតបៀនកុំអោយមានជំងឺដង្កាត់អី
ហើយសូមប្រកបការងាររដ្ឋនឹងអោយបានឡើងបុណ្យឡើងសាក់អីទាំងអស់គ្នាកុំអោយមានសត្រូវមកបៀតបៀនបានឡើយណាស់ទានណាស់!

គៈ សុខចំរើន! (សំលេងរបស់លោកយាយ)!

ខៈ ទៅទីណាអោយឈ្នះមាសត្រូវទាំងអស់ណាស់! (មានសំលេងរំខានពីខាងក្រៅ)!

កៈ ចាសលោកតា!

ខ៖ បាទ!!

ក៖ ចាសអញ្ចឹងជាចុងក្រោយនឹងតើលោកតាធ្វើការអនុញ្ញាតយកសំលេងរបស់លោកតាយកហើយនឹងរូបភាពរបស់លោកតាទៅដាក់នៅក្នុងវេបសាយរបស់ខាងសាលាបានដែរឬទេលោកតា?

ខ៖ បាទៗ មានអីនាង!

ក៖ ចាសអរគុណច្រើនលោកតា!